# ទស្សនាវដ្ដី

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

*THE NGO FORUM ON CAMBODIA*

ឆ្នាំទី០៣ លេខទី០៤ ខែមិថុនា ឆ្នាំ២០០៦











ទស្សនាវដ្ដី

# វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

លេខ ០៩ ខែកក្កដា ឆ្នាំ២០០៦

## មាតិកា

យេនឌ័រ និងការរកប្រាក់ចំណូល.... ..................................ទំព័រទី ១

វាលរហោស្ថាន និងរហោស្ថានកម្ម. ..................................ទំព័រទី ៣

ចំណាកស្រុកបណ្ដាលអោយកសិករទទួលគ្រោះថ្នាក់ពីថ្នាំកសិកម្ម....... ..................................ទំព័រទី ៥

ករណីសិក្សា កសិករភ្ញាក់រលឹកឈប់ប្រើប្រាស់ថ្នាំកសិកម្ម........ទំព័រទី ៧

ទទួលស្គាល់ដោយគ្មានព្រំដែនចំពោះជនរងគ្រោះដោយសារទំនប់វារីអគ្គិសនី............................ទំព័រទី ៨

ផលប៉ះពាល់ពីបញ្ហាព្រៃឈើ ដីធ្លី ជនជាតិដើមភាគតិច និងបរិស្ថាន នៅខេត្តព្រះវិហារ.....ទំព័រទី ១១

វិធីបំបាក់ស្មារតីដោយការបង្ក្រាបដោយចោទថាជាបទល្មើសជាក់ស្ដែង ..............................ទំព័រទី ១៤

តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងការទប់ស្កាត់អំពើពុករលួយ............. ..............................ទំព័រទី ១៧

---

**គណៈកម្មការត្រួតពិនិត្យ**

-លោក **ឈិត សំអាត**

-លោក **ទី សន**

-លោក **ឯក ស៊ីដេន**

-លោក **ទូច សុខា**

## អារម្ភកថា

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា (NGO Forum) មានវត្តមានដើម្បីចែករំលែកពត៌មាន ពិភាក្សា និងធ្វើការតស៊ូមតិលើបញ្ហាអទិភាពនានាដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍នៅកម្ពុជា ។ NGO Forum ចង់ឃើញប្រទេសកម្ពុជាមានប្រជាពលរដ្ឋរបស់ខ្លួនដែលជ្រួតជ្រាបអំពីពត៌មានទាំងឡាយ ព្រមទាំងបានទទួលការផ្ដល់អំណាចឱ្យចូលរួមក្នុងសង្គមស៊ីវិលដ៏ត្រចះត្រចង់ និងរឹងប៉ឹងមួយដើម្បីផ្ដល់ផលប្រយោជន៍ដល់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ។ NGO Forum ជំរុញអង្គការសមាជិករបស់ខ្លួន និងអង្គការទាំងអស់ដទៃទៀតឱ្យធ្វើការរួមគ្នាដើម្បីនិយាយពាក្យជាធ្លុងមួយដ៏មានឥទ្ធិពលដើម្បីការពារប្រយោជន៍ និងសិទ្ធិរបស់ជនក្រីក្រ ។ NGO Forum គឺជាអង្គការសមាជិកភាពមួយសំរាប់ទាំងអង្គការក្នុងស្រុកនិងអន្តរជាតិទាំងឡាយ ។ ជោគជ័យរបស់ NGO Forum គឺពឹងផ្អែកទាំងស្រុងទៅលើការខិតខំរបស់អង្គការសមាជិក ។ ទស្សនាវដ្ដីនេះមានបំណងចងក្រងសមិទ្ធផលនានារបស់អង្គការសមាជិកទាំងឡាយក៏ដូចជា ដើម្បីផ្ដល់ពត៌មានថែមទៀតទាក់ទិននឹង ***ការងារអភិវឌ្ឍន៍ បរិស្ថាន ដីធ្លី និងការចិញ្ចឹមជីវិត*** និង***បញ្ហាយេនឌ័រ*** ដល់អ្នកអានទូទៅដោយរាប់បញ្ចូលប្រជាពលរដ្ឋនៅក្នុងខេត្តដាច់ស្រយាលនានាផងដែរ ។ ទស្សនាវដ្ដីនេះមានគោលបំណងពិសេសក្នុងការ:

- លើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តការរវាងអង្គការសមាជិកទាំងអស់របស់ NGO Forum ។
- បង្កើនការយល់ដឹងដល់ពលរដ្ឋកម្ពុជា អំពីបញ្ហានានានៃការអភិវឌ្ឍន៍កំពុងតែកើតឡើងដែលអាចប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ។ និង
- លើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការបង្កើត និងការកែលំអគោលនយោបាយដែលអាចប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ។

NGO Forum សូមស្វាគមន៍នូវការចូលរួមចំណែកផ្ដល់អត្ថបទសំរាប់ទស្សនាវដ្ដីនេះ និងសូមស្វាគមន៍រាល់មតិរិះគន់ដើម្បីកែលំអនានា ។

## PREFACE

The NGO Forum exists for information sharing, debate and advocacy on priority issues affecting Cambodia's Development. The NGO Forum wants to see Cambodia will have a well-informed and empowered population participating in a strong and vibrant civil society, to the benefit of poor and vulnerable people in Cambodia. The NGO Forum approaches to all its member organizations and active not-member organizations for working together to collate a strong one voice for protecting the underlying benefits of the poor. The NGO Forum is a membership organization for local and international NGOs, which owes its success to the efforts of its members. In the future, this magazine intends to compile the achievements of member organizations as well as to provide more information regarding ***development***, ***environment***, ***land*** and ***livelihoods***, and ***gender*** issues to a broader audience, including to people in remote provinces. Specific objectives of the magazine are as follows:

- To encourage collaboration among the member organizations of the NGO Forum;
- To increase the awareness of Cambodian people about contemporary development issues which affect their lives; and
- To promote people's participation in policy developments and reforms that may affect their lives.

The NGO Forum on Cambodia welcomes contributive articles from member organizations and any constructive criticism for improvement.

# វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

## ទស្សនៈវិស័យ

ប្រទេសកម្ពុជានឹងមានប្រជាពលរដ្ឋដែលប្រកបដោយការចេះដឹង និងមានសិទ្ធិអំណាចគ្រប់គាន់ចូលរួមនៅក្នុងសង្គមស៊ីវិលមួយដែលរឹងមាំ និងរស់រវើក ។

## បេសកកម្ម

**NGO Forum** រួមមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ដែលមានបទពិសោធន៍នៅក្នុងការផ្តល់ជំនួយមនុស្សធម៌និងជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា។ NGO Forum បង្កើតឡើងដើម្បីចែករំលែកពត៌មានគ្នា ពិភាក្សាដេញដោល និងតស៊ូមតិលើបញ្ហាជាអាទិភាពនានា ដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ NGO Forum មានតួនាទីយ៉ាងសំខាន់នៅក្នុងការលើកឡើងនូវគោលសំខាន់នានា ដែលប៉ះពាល់ដល់ដំណើរការអភិវឌ្ឍន៍ និងការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គម និងនយោបាយដែលមានទៅលើប្រជាជនកម្ពុជា ។

## គុណតំលៃ

NGO Forum មានជំនឿទៅលើភាពធ្វើការរួមគ្នាដើម្បី:

- យុត្តិធម៌ផ្នែកសេដ្ឋកិច្ចនិងសង្គម
- ការគោរពសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ
- សមភាពផ្នែកយេនឌ័រ
- សន្តិភាព និងអហិង្សា
- ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- ការគោរពដល់វប្បធម៌ផ្សេងៗគ្នា និង
- ការអភិវឌ្ឍន៍ប្រកបដោយសមធម៌

## គោលដៅ

សំរាប់ផែនការសកម្មភាពឆ្នាំ២០០៦-២០០៨ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ផ្តោតលើគោលដៅតែមួយគត់គឺ :

*"សិទ្ធិរបស់អ្នកក្រនិងក្រុមដែលងាយរងគ្រោះនៅប្រទេសកម្ពុជា ត្រូវបានទទួលស្គាល់និងគាំទ្រដោយនយោបាយនិងការអនុវត្តន៍ផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រទេសផ្តល់ជំនួយនិងដោយសហគមន៍ទាំងមូល។"*



បងស្រី ម៉ូត អាម៉ីណាស់ និងអាជីវកម្មខ្នាតតូចរបស់គាត់

# យេនឌ័រ និងការរកប្រាក់ចំណូល

បងស្រី ម៉ូត អាម៉ីណាស់ អាយុ ៤៥ ឆ្នាំ ជាជនជាតិខ្មែរឥស្លាម មានមុខរបរជាអ្នករកស៊ីលក់ត្រី ប្តីឈ្មោះ លីម ឯល អាយុ ៤៨ ឆ្នាំ មានមុខរបរជាអ្នករត់ម៉ូតូឌុប និងលក់ទឹកអំពៅ មានកូនចំនួន ៦ នាក់ ស្រី ៣ នាក់ និងប្រុស ៣ នាក់នៅក្នុងបន្ទុក ។ គាត់មានទីលំនៅនៅក្នុងភូមិ ៤ សង្កាត់ច្រាំងចំរេះ ១ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ សង្កាត់ច្រាំងចំរេះ ១ គឺជាសង្កាត់ដែលសំបូរទៅដោយជនជាតិខ្មែរឥស្លាម រស់នៅយ៉ាងច្រើនកុះករ ។ ក្នុងចំណោមគ្រួសារខ្មែរឥស្លាមដែលរស់នៅក្នុងភូមិ ៤ នេះ មានច្រើនគ្រួសារទៀតដែលមានជីវភាពរស់នៅប្រហាក់ប្រហែលនឹងករណីដែលយើងបានលើកមកនេះ តែគ្រួសារបងស្រីម៉ូត អាមីណាស់ ជាគ្រួសារក្រីក្រមួយនៅក្នុងភូមិដែលខិតខំតស៊ូរកស៊ីយ៉ាងលំបាក ដើម្បីបានកំរៃចិញ្ចឹមកូនទាំង ៦ និងគ្រួសាររបស់គាត់ ។

ចាប់តាំងចេញពីរបបខ្មែរក្រហមឆ្នាំ១៩៧៩ មក បងស្រីម៉ូត អាម៉ីណាស់ ពុំបានប្រកបមុខរបរអ្វីទេ គាត់មានតួនាទីជាមេផ្ទះ ជាអ្នកថែទាំកូន និងបេះត្រកួនលក់បន្តិចបន្តួច គឺរស់ដោយសារប្តីគាត់រកស៊ីចិញ្ចឹមតែប៉ុណ្ណោះ ។ នៅកំឡុងឆ្នាំ១៩៩០ ដល់ឆ្នាំ១៩៩៦ ប្តីបងស្រីបានឈប់ប្រកបរបររកស៊ីកាប់ឈើខុសច្បាប់មករកស៊ីរត់ម៉ូតូឌុបនៅក្បែរផ្ទះវិញ ដោយរួមផ្សំទៅនឹងមុខរបរលក់ដូរតូចតាចរបស់គាត់ ។ ប៉ុន្តែមុខរបរទាំងអស់នេះមិនអាចធ្វើឱ្យជីវភាពគ្រួសារគាត់បានប្រសើរឡើយ គឺកាន់តែធ្វើអោយជីវភាពធ្លាក់ចុះយ៉ាងខ្លាំងបន្ថែមទៅទៀត គឺគាត់បានខ្ចីប្រាក់ពីឈ្មួញឯកជនដែលមានអត្រាការប្រាក់ខ្ពស់យកមករកស៊ី ។ ប្រាក់ចំណូលដែលគាត់រកបានប្រចាំថ្ងៃពុំគ្រប់គ្រាន់ទៅនឹងការចំណាយទេ គឺគាត់ត្រូវចំណាយទៅលើការរៀនសូត្ររបស់កូន ការហូបចុក ការប្រាក់ និងការចំណាយផ្សេងៗក្នុងគ្រួសារ ។

នៅឆ្នាំ១៩៩៧ អង្គការអភិវឌ្ឍន៍ស្ត្រីកម្ពុជា បានចូលទៅដាក់កម្មវិធីអភិវឌ្ឍន៍សហគមន៍នៅក្នុងសង្កាត់ច្រាំងចំរេះ ១ លើកម្មវិធីឥណទានដើម្បីលើកតម្កើងតួនាទីស្ត្រីក្នុងគ្រួសារ និងក្នុងសង្គម ដោយធ្វើការលើកកំពស់សេដ្ឋកិច្ចគ្រួសារ និងជីវភាពរស់នៅតាមរយៈការអប់រំផ្សព្វផ្សាយ ការកសាងសមត្ថភាព និងបង្កើតជំនាញ ព្រមទាំងសកម្មភាពស្វែងរកប្រាក់ចំណូលផ្សេងៗ ។ ពេលនោះក្រុមគ្រួសារបងស្រីក៏បានចូលរួមក្នុងការងារអភិវឌ្ឍន៍សហគមន៍របស់គាត់គឺចូលរួមជាសមាជិកក្នុងក្រុមស្ត្រី ។ ក្រុមស្ត្រីមានតួនាទីសិក្សាស្វែងយល់ កំនត់ និងវិភាគនូវបញ្ហាដែលទាក់ទងទៅនឹងបញ្ហាជីវភាពរស់នៅរបស់គ្រួសារនិមួយៗ និងលើកជាផែនការសកម្មភាពដែលអាចឆ្លើយតបទៅនឹងតំរូវការជាក់ស្តែង ។ ក្រុមស្ត្រីបានផ្តល់យោបល់ឱ្យបងស្រីពីការបង្កើតមុខរបររកប្រាក់ចំណូលផ្សេងៗ តាមរយៈការចងក្រងជាក្រុម ដើម្បីទទួលប្រាក់កំចីពីអង្គការ ។

នាពេលបច្ចុប្បន្ននេះ បងស្រី និងប្តីរបស់គាត់បានពង្រីកមុខរបរបន្ថែមទៀត ដើម្បីរួមផ្សំទៅនឹងមុខរបរលក់ត្រីដូចជា លក់នំចំណី និងបន្លែផ្សេងៗទៀត ។ ពេលណាត្រីស្រស់លក់នៅសល់ គាត់តែងតែប្រឡាក់ហាល រួចទួលយកទៅលក់តាមតូបក្នុងផ្សារឬតាមផ្ទះ ។ ជាទូទៅគាត់តែងតែផ្លាស់ប្តូរមុខរបរទៅតាមពេលវេលា និងការនិយមចូលចិត្តរបស់អ្នកភូមិ ។ បើមើលទៅលើជីវភាពរបស់គាត់វិញ គឺមានការរីកចំរើនគួរអោយកត់សំគាល់មួយកំរិតទៀត ដោយសព្វថ្ងៃនេះ គាត់បានទិញម៉ាស៊ីនកិនទឹកអំពៅដែលតម្លើងភ្ជាប់ជាមួយម៉ូតូសំរាប់ឱ្យប្តីគាត់ជិះយកទៅលក់នៅតាមរោងចក្រកាត់ដេរ ។



លោក Russell Peterson និង [illegible] ក្នុងក្បួនដង្ហែទិវាបរិស្ថាន ឆ្នាំ២០០៦

ក្រោយ ។ ពិធីនេះក៏មានការហែរក្បួនផងដែរ ដើម្បីទាញចំណាប់អារម្មណ៍ពីសាធារណជនទៅលើបញ្ហាបរិស្ថាន ។ ផែនក្បួនត្រូវបានរៀបចំឡើងដោយមានសមាសភាគជាច្រើនដូចជា គណៈអធិបតី ព្រះសង្ឃ ក្រុមកាយឬទ្ធិនារីកម្ពុជា ក្រុមពាក់មុខសត្វផ្សេងៗ ធ្វើយ៉ាងណាអោយមានភាពប្លែកៗ ជាមួយនិងជ័យឃោសស្នូរស័ព្ទយ៉ាងគគ្រឹកគគ្រេងតាមបណ្តោយមហាវិថីធំៗ ដូចជាមហាវិថីនរោត្តម និងព្រះសីហនុ និងបណ្តាផ្លូវផ្សេងៗទៀតដោយមានមនុស្សម្នា អ្នកធ្វើដំណើរទៅមកយ៉ាងច្រើនកុះករ បានដឹង បានឮ នូវខ្លឹមសារ និងអត្ថន័យនៃការរៀបចំទិវានេះ ។ ការរៀបចំទិវានេះ អាចប្រព្រឹត្តទៅបានដោយជោគជ័យក៏ដោយសារតែមានការចូលរួមសហការពីបណ្តាសមាជិកបរិស្ថាន និងជាពិសេសពីបណ្តាអ្នកឧបត្ថម្ភធំៗដូចជា អង្គការ NGO Forum, Forum Syd, DPA, Caritas-Cambodia, LWF, CSARO ដែលបានគាំទ្រផ្នែកថវិកា និងទាំងកំលាំងកាយកំលាំងចិត្តក្នុងការរៀបចំទិវានេះក្នុងបុព្វហេតុលើកកំពស់ការយល់ដឹង និងកិច្ចការពារបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីរួមចំណែកកាត់បន្ថយនូវវិនាសកម្មបរិស្ថាននេះ យើងជាប្រជាជនកម្ពុជាត្រូវតែមានភាតព្វកិច្ចចូលរួមចំណែកក្នុងការទប់ស្កាត់នូវបញ្ហាដូចដែលបានលើកឡើងខាងលើដើម្បីជាប្រយោជន៍ដល់កូនចៅរបស់យើងទៅថ្ងៃអនាគត ។ ដូច្នេះយើងទាំងអស់គ្នាមេត្តាបញ្ឈប់នូវរាល់ការបំផ្លិចបំផ្លាញបរិស្ថានតាមគ្រប់រូបភាព ហើយរួបរួមគ្នាការពារនូវធនធានធម្មជាតិទាំងឡាយអោយស្ថិតស្ថេរជានិច្ចនិរន្តរ៍តទៅ ។ សូមឧទ្ទិសអោយទិវានេះដក់ជាប់នៅក្នុងអារម្មណ៍របស់ប្រជាពលរដ្ឋកម្ពុជាគ្រប់ជំនាន់ដើម្បីប្រកាន់យកនូវស្មារតីថែរក្សា ការពារ អភិវឌ្ឍន៍ និងអភិរក្សនូវធនធានធម្មជាតិរបស់ប្រទេសជាតិយើង ។

*អត្ថបទដោយលោក* ***សំ ចាន់ធី*** *មន្ត្រីគំរោងបរិស្ថាន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*



ក្បួនដង្ហែទិវាបរិស្ថាន

# ចំណាកស្រុកបណ្ដាលអោយកសិករ ទទួលគ្រោះថ្នាក់ពីថ្នាំកសិកម្ម

នៅថ្ងៃទី១៩-២១ ខែមិថុនា ឆ្នាំ២០០៦ **បណ្ដាញកាត់បន្ថយថ្នាំកសិកម្មនៅកម្ពុជា** បានសហការជាមួយសមាគមអភិវឌ្ឍន៍បង្កើនសេដ្ឋកិច្ចគ្រួសារ បានចុះទៅពិនិត្យស្ថានភាពជាក់ស្ដែងនៅភូមិតានូ និងភូមិទួលខ្ពស់ ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង។ ផ្ទៃដីសរុបទូទាំងខេត្តចំនួន ២៩៦,៦៤០ ហិកតា ដែលមានផ្ទៃដីដាំស្រូវវស្សា និងស្រូវប្រាំងសរុបចំនួន ១៧៥,០០០ ហិកតា ក្នុងនោះស្រូវវស្សាចំនួនចំនួន ១៦២,៣០០ ហិកតា និងស្រូវប្រាំងចំនួន ១២៥,៧០០ ហិកតា។ សរុបផ្ទៃដីកសិកម្ម (ស្រែ និងដំណាំ) ចំនួន ១៨៥,០០០ ហិកតា។ ចាប់តាំងពីឆ្នាំ២០០០ រហូតមកដល់សព្វថ្ងៃបញ្ហាគ្រោះធម្មជាតិកើតឡើងជាញឹកញាប់ដូចជា គ្រោះរាំងស្ងួត និងទឹកជំនន់ ជាពិសេសគ្មានប្រព័ន្ធធារាសាស្ត្រ។ ប្រជាជនធ្វើស្រែពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ហេតុនេះប្រជាជនទទួលបានទិន្នផលទាប ពុំអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានគ្រប់គ្រាន់ទើបបណ្ដាលឱ្យប្រជាជនខ្លះធ្វើចំណាកស្រុកទៅរកស៊ីទៅប្រទេសវៀតណាម និងខេត្តផ្សេងៗ។ ចំពោះប្រជាជនធ្វើចំណាកស្រុកទៅរកស៊ីនៅប្រទេសវៀតណាម គឺបុរសស៊ីឈ្នួលបាញ់ថ្នាំកសិកម្ម និងបាចជីឯនារីស៊ីឈ្នួល ស្ទូង ច្រូត និងដើររើសស្រូវ។ សំរាប់ការងារដែលបានរៀបរាប់ខាងលើនេះកសិករយើងទទួលបានប្រាក់កំរៃពី ៥,០០០ ទៅ ១០,០០០ រៀលក្នុងមួយថ្ងៃ និងពេលខ្លះគាត់ទទួលបានតិចជាងនេះក៏មានដែរ។ កត្តាទាំងអស់នេះធ្វើឱ្យប្រជាជនទទួលរងនូវឥទ្ធិពលថ្នាំកសិកម្មយ៉ាងខ្លាំងទៅលើសុខភាព ព្រោះវៀតណាមប្រើប្រាស់ជីគីមី និងថ្នាំកសិកម្មយ៉ាងខ្លាំងលើដំណាំដែលលាយបញ្ចូលគ្នាច្រើនមុខ (៦ ទៅ ៨ ប្រភេទ) និងគ្មានបច្ចេកទេសការពារខ្លួនឡើយ។ កសិករខ្លះបាញ់ថ្នាំនៅប្រទេសវៀតណាមរយៈពេលពី ៥ ទៅ ១០ ឆ្នាំ និងខ្លះលើសពីនេះទៅទៀត។ បច្ចុប្បន្នសុខភាពប្រជាជនមានការទ្រុឌទ្រោម និងចុះខ្សោយជាលំដាប់ព្រមទាំងបានជះឥទ្ធិពលទៅដល់កូនចៅជំនាន់ក្រោយទៀតផង។ តាមលោក ម៉ៅ មាន មេឃុំចំបក់ បានមានប្រសាសន៍ថា អ្នកស៊ីឈ្នួលបាញ់ថ្នាំឱ្យវៀតណាមស្លាប់ចំនួន ៣ នាក់ ក្នុងរយៈពេល ៣ ឆ្នាំ ក្រៅពីស្លាប់អ្នកខ្លះមានជំងឺ ទ្រុឌទ្រោម និងមួយចំនួនទៀតដេកដួលនៅលើផ្ទះពុំអាចធ្វើការអ្វីបានឡើយ។ មានគ្រួសារមួយចំនួនកូនកើតមកមានរាងកាយខ្វិន ទន់ដៃជើងដើរពុំកើត។ ម្យ៉ាងវិញទៀតបើតាមការសង្កេតរបស់លោក បន្លែ និងសាច់ជ្រូកភាគច្រើននាំចូលពីវៀតណាម ផលិតផលទាំងនេះប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមី ហើយមានតំលៃថោកជាងបន្លែ និងសាច់ជ្រូកនៅកម្ពុជា ដូច្នេះកសិករក្រីក្រងាកមកទិញបន្លែ និងសាច់ជ្រូកពីវៀតណាមដែលធ្វើឱ្យគាត់មានជំងឺទាំងពេលបច្ចុប្បន្ន និងពេលអនាគត។ លោកបានផ្សព្វផ្សាយពីគ្រោះថ្នាក់របស់ថ្នាំកសិកម្មទៅលើសុខភាពឱ្យប្រជាជនបានយល់ដឹងខ្លះៗដើម្បីឱ្យពួកគាត់កាត់បន្ថយការប្រើប្រាស់កសិកម្មប្រជាជនយល់ថាមិនប្រើប្រាស់ថ្នាំកសិកម្មក៏ស្លាប់ប្រើប្រាស់ថ្នាំកសិកម្មក៏ស្លាប់ (ព្រោះគ្មានជំរើស) ដូច្នេះពួកគាត់ជ្រើសរើសយកការប្រើប្រាស់ថ្នាំកសិកម្ម។ តាមការសាកសួរ និងសង្កេតទូទៅរោគសញ្ញាដែលកើតមានទៅលើប្រជាជននៅតំបន់នោះរួមមាន:

១. កន្ទួល រមាស់ ចាប់ពីចុងជើងដល់ផងខ្លួន
២. របកក្រចកដៃ ជើង
៣. ក្អួត ចង្អោរ រាគរូស ឈឺក្បាល វិលមុខ ហើមពោះ ស្រវាំងភ្នែក ហើម
៤. ស្ពឹកពេញខ្លួន
៥. ធ្លាក់ឈាម ក្អកចេញឈាម
៦. ពិការ ស្លាប់



ថ្នាំកសិកម្មលក់នៅតាមព្រំដែនប្រទេសកម្ពុជា


ផលប៉ះពាល់ថ្នាំកសិកម្មបណ្ដាលអោយរបូតក្រចកដៃ


ការបាញ់ថ្នាំកសិកម្មខុសបច្ចេកទេស

ប្រជាជន និងអជ្ញាធរសំណូមពរដល់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនូវចំណុចមួយចំនួនដូចខាងក្រោម:

- សូមអោយបើកវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសកសិកម្ម ។
- សូមអោយមានការរៀបចំសិក្ខាសាលាដើម្បីបង្កើនការយល់ដឹងពីផលប៉ះពាល់ថ្នាំកសិកម្ម ។
- សូមអោយជួយរកជំរើសផ្សេងៗ ក្នុងការបង្កើនមុខរបរបន្ថែមជូនប្រជាជននៅតំបន់នេះ (ដូចជាបណ្តុះបណ្តាលការចិញ្ចឹមសត្វ សិប្បកម្មបច្ចេកទេសដាំដុះ និងបង្កើនទីផ្សារ) ។
- សូមអោយរដ្ឋាភិបាលជួយទប់ស្កាត់ផលិតផលនាំចូលដើម្បីបង្កើនតំលៃផលិតផលក្នុងស្រុក ។
- រដ្ឋាភិបាលត្រូវរៀបចំប្រព័ន្ធធារាសាស្ត្រអោយបានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ការស្រោចស្រពលើផ្ទៃដីកសិកម្មរបស់ប្រជាជន ។
- រដ្ឋាភិបាលត្រូវជំរុញឱ្យកុមារបានចូលរៀនទាំងអស់គ្នា ដោយអនុវត្តទៅតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺការអប់រំសំរាប់ទាំងអស់គ្នា (Education For All) និងផ្តល់នូវសេវាសុខភាពឱ្យបានសមរម្យ ។

*អត្ថបទដោយ កញ្ញា* ***ម៉ែន វណ្ណារី*** *មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្ម វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*



កុមារីនេះខ្វិនជើងដោយសារផលប៉ះពាល់ថ្នាំកសិកម្ម



កុមារីនេះទន់ដៃ ជើង ដោយសារផលប៉ះពាល់ថ្នាំកសិកម្ម

# ករណីសិក្សា

## កសិករភ្ញាក់រលឹកឈប់ប្រើប្រាស់ថ្នាំកសិកម្ម

មីង ប្រែង កាន ជាកសិករ គាត់មានប្ដីឈ្មោះ អ៊ំ លុច និងកូន ៤ នាក់ រស់នៅភូមិគោកដូង ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ជាធម្មតាគាត់តែងតែដាំដំណាំបន្លែដូចជា ចៃស៊ុម ស្ពៃស ស្ពៃក្ដោប ខាត់ណា ដើម្បីលក់នៅក្នុងភូមិ និងឈ្មួញមកទិញដល់ផ្ទះ ។

រាល់ការដាំដុះដំណាំបន្លែទាំងនេះតែងតែទទួលរងនូវការបំផ្លាញពីសត្វល្អិតផ្សេងៗដូចជា ដង្កូវឃោងទោង ដង្កូវកាត់ស្លឹក ដង្កូវហ្វូង ដង្កូវ ស៊ីបណ្ដូល ហើយប្ដីរបស់គាត់ប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមីកសិកម្មដើម្បីការពារដំណាំរបស់គាត់ជារៀងរហូតមក ។

មីង កាន បានរៀបរាប់ប្រាប់អោយបានដឹងថា ប្ដីរបស់គាត់បានប្រើប្រាស់ថ្នាំកសិកម្មរយៈពេល ១០ ឆ្នាំមកហើយ ។ ការប្រើប្រាស់ថ្នាំកសិកម្មមិនទៅតាមលក្ខណៈបច្ចេកទេសទេគឺតាមរយៈពីកសិករមួយទៅកសិករមួយទៀត ហើយការប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ រីឯការចំណាយកាន់តែច្រើនដោយសារសត្វល្អិតដែលបំផ្លាញដំណាំរបស់គាត់កាន់តែកើនឡើង ព្រោះវាមានភាពស៊ាំទៅនឹងប្រភេទថ្នាំកសិកម្មដែលគាត់បានប្រើ ។ ថ្នាំកសិកម្មដែលប្ដីរបស់គាត់ប្រើមានដូចជាៈ ថ្នាំហ្វូលីដុល ថ្នាំរូបផ្លិត និងថ្នាំរូបទង់ជ័យ (ឈ្មោះកសិករហៅ) ការចំណាយទៅលើការទិញថ្នាំកសិកម្មអស់ប្រហែល ៤០ ម៉ឺន ទៅ ៥០ ម៉ឺនរៀលក្នុងមួយឆ្នាំ ព្រោះ ៣ ថ្ងៃបាញ់ម្ដង ។ បន្ទាប់ពីបាញ់ថ្នាំរួច ៣ ថ្ងៃ មីង កាន កាត់យកទៅលក់ ព្រោះបន្លែមើលទៅល្អ មិនទទួលរងការបំផ្លាញពីសត្វល្អិតទេ តែគាត់ពុំបានដឹងពីផលប៉ះពាល់ថ្នាំកសិកម្មនៅក្នុងបន្លែទៅដល់អ្នកបរិភោគនោះទេ ។

មីង កាន បានរៀបរាប់ថា ប្ដីរបស់គាត់ធ្លាប់ពុលថ្នាំកសិកម្ម គឺធ្វើអោយប្ដីគាត់ងងឹតមុខ ណែនទ្រូង ហើយមិនត្រឹមតែប៉ុណ្ណោះប្ដីរបស់គាត់សន្លប់ដោយសារបើកគំរបដបថ្នាំកសិកម្ម (ត្រាផ្លិត) ។ នៅពេលបាញ់ថ្នាំម្ដងៗ ប្ដីរបស់គាត់ពុំបានពាក់ឧបករណ៍ការពារអ្វីទេគឺស្លៀកខោខ្លី និងអាវដៃវែង ។

ក្រោយពីបានទទួលការអប់រំពីអង្គការអភិវឌ្ឍន៍ស្ត្រី និងចូលរួមសិក្ខាសាលាបង្កើនការយល់ដឹងពីផលប៉ះពាល់ថ្នាំកសិកម្មរួចមក មីង កាន និងប្ដីរបស់គាត់បានប្ដេជ្ញាឈប់ប្រើប្រាស់ថ្នាំកសិកម្ម ហើយងាកមកប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិវិញ ។ ចំណែករូប មីង កាន វិញ ឈប់នៅទំនេរទៀតហើយ គាត់ទៅរកត្រី និងបេះសណ្ដែក ព្រោះពីមុនគាត់នៅពីក្រោមខ្យល់ ហើយទទួលនូវឥទ្ធិពលពីការបាញ់ថ្នាំរបស់ប្ដីគាត់ ។

សូមបញ្ជាក់ថា នេះជាការភ្ញាក់រលឹករបស់កសិករដែលប្រើប្រាស់ថ្នាំកសិកម្មអស់រយៈពេលជិត ១០ ឆ្នាំមកហើយ និងទទួលផលប៉ះពាល់ពីថ្នាំកសិកម្មរហូតដល់សន្លប់ ។ សូមកសិករទាំងឡាយដែលធ្លាប់ប្រើប្រាស់ថ្នាំកសិកម្ម និងកំពុងប្រើប្រាស់សូមភ្ញាក់រលឹកឈប់ប្រើប្រាស់ថ្នាំកសិកម្ម ហើយងាកមកប្រើប្រាស់ថ្នាំផ្សំពីរុក្ខជាតិវិញ ព្រោះវាចំណេញទាំងថវិកា និងសុខភាព ។

*អត្ថបទដោយ កញ្ញា **ម៉ែន វណ្ណារី** មន្ត្រីគំរោងកាត់បន្ថយថ្នាំកសិកម្ម វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា ។*



កសិករកម្ពុជាទៅស៊ីឈ្នួលបាញ់ថ្នាំកសិកម្មនៅប្រទេសវៀតណាម

# ទទួលស្គាល់ដោយគ្មានព្រំដែនចំពោះជនរងគ្រោះដោយសារទំនប់វារីអគ្គិសនី

កាលពីខែកន្លងមកនេះ ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត បានធ្វើការប្ដេជ្ញាចិត្តយ៉ាងសំខាន់ដែលពាក់ព័ន្ធនឹងប្រជាជនកម្ពុជារាប់ពាន់នាក់ ដែលរងគ្រោះឬត្រូវគំរាមកំហែងដោយការកសាងវារីអគ្គិសនីដែលគាំទ្រដោយ Nordic ។ ឆ្លើយតបទៅនឹងសំណើរបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា ទីប្រឹក្សាផ្នែកថាមពលរបស់ Sida លោក Goran Hag បានប្រកាសថា ទាំង Sida និងដៃគូរបស់ខ្លួនមកពីប្រទេសណ័រវេស៍ (NORAD) នឹងគាំទ្រការពិគ្រោះយោបល់ជាសាធារណៈមួយស្ដីពីផលប៉ះពាល់មកលើ (ប្រជាជនកម្ពុជា) នៅខ្សែទឹកខាងក្រោមដែលបណ្ដាលមកពីការកសាងវារីអគ្គិសនីនៅតាមបណ្ដោយទន្លេសេសាន និងទន្លេស្រែពក ។ ជាពិសេស SIDA និង NORAD បានយល់ព្រមផ្ដល់ថវិកាសំរាប់ការចូលរួមរបស់អ្នកជំនាញការទាំងឡាយដែលបានរៀបចំការវាយតំលៃផលប៉ះពាល់បរិស្ថានទាពេលថ្មីៗនេះ (EIA) ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលអាចកើតមានដោយសារការកសាងវារីអគ្គិសនីនៅលើទន្លេស្រែពក ។

ការពិគ្រោះយោបល់នេះ ជាមួយជនរងគ្រោះដោយសារការកសាងទំនប់ និងអ្នកពាក់ព័ន្ធកម្ពុជាផ្សេងទៀត គឺហួសពេលជាង ១០ឆ្នាំមកហើយ ប៉ុន្តែសុខចិត្តយឺត ជាជាងគ្មានសោះ ។ វាមិនត្រឹមតែអាចកែប្រែនូវការមិនអើពើអស់រយៈពេលមួយទសវត្ស ដោយដៃគូវារីអគ្គិសនីដែលគាំទ្រថវិកាដោយប្រទេស Nordic នោះទេ ប៉ុន្តែថែមទាំងអាចកំណត់នូវស្តង់ដាថ្មីមួយសំរាប់អ្នកកសាងទំនប់ និងការគ្រប់គ្រងទន្លេនៅក្នុងមហាតំបន់ទន្លេមេគង្គ ។

ជាបឋម នេះគឺជាប្រវត្តិខ្លះៗ: ទន្លេដែលមានបញ្ហានេះ ហូរចាក់មកទិសបស្ចឹមចេញមកពីតំបន់ខ្ពង់រាបកណ្ដាលនៃប្រទេសវៀតណាមចុះមកប្រទេសកម្ពុជាតាមភាគឦសានក្នុងចំងាយប្រហែលពីរបីគីឡូម៉ែត្រមុននឹងមកប្រសព្វជាមួយទន្លេមេគង្គ ។ ប្រជាជនរាប់ម៉ឺននាក់ដែលរស់នៅតាមតំបន់ទន្លេទាំងនេះ ភាគច្រើនជាកសិករដែលពឹងផ្អែកទាំងស្រុងទៅលើទន្លេទាំងនេះ និងព្រៃឈើដែលនៅព័ទ្ធជុំវិញនោះសំរាប់ជាអាហារនិងប្រាក់ចំណូល ។ បញ្ហារបស់ប្រទេសកម្ពុជាជាមួយនឹងការកសាងវារីអគ្គិសនីនេះបានចាប់ផ្ដើមតាំងពីចុងទសវត្សឆ្នាំ១៩៩០ នៅពេលដែលអ្នកប្រតិបត្តិការទំនប់យ៉ាលី ( Yali Falls ) ដែលជាទំនប់លើកទីមួយ និងធំបំផុតនៅលើទន្លេសេសានដែលមានចំងាយប្រមាណ ៧០ គ.ម ពីព្រំដែនប្រទេសកម្ពុជាបានបើកបង្ហូរទឹកបង្កអោយមានទឹកជំនន់ដែលគ្រោះថ្នាក់ដល់អាយុជីវិតជាបន្តបន្ទាប់ហើយត្រូវបានអះអាងថាបានសំលាប់ប្រជាជនកម្ពុជាជាង ៣០ នាក់[១] និងបានហូរនាំយកទៅនូវសត្វធាតុ ទូក អនុផល ឧបករណ៍ចាប់ត្រី និងទ្រព្យសម្បត្តិជាច្រើនទៀត ។ គ្មានសំណងណាមួយត្រូវបានផ្ដល់ជូនដោយម្ចាស់ទំនប់គឺអគ្គិសនីវៀតណាម (Electricity of Vietnam-EVN) ។ គ្មានការវាយតំលៃអំពីការរងរបួស ឬការខូចខាតជាផ្លូវការត្រូវបានធ្វើឡើង ។ ផ្ទុយទៅវិញ EVN នៅតែបន្តសាងសង់ទំនប់បន្ថែមទៀតនៅលើទន្លេសេសាន និងពន្លឿនផែនការសំរាប់កសាងទំនប់ ៦ ទៀតនៅលើទន្លេស្រែពកដែលជាទន្លេធំទីពីរជាប់ព្រំដែនប្រទេសទាំងពីរ ។ ហើយអគ្គិសនីវៀតណាមធ្វើដូច្នេះ

---

[១]ការិយាល័យជលផល និងគំរោងផលិតផលព្រៃឈើមិនមែនឈើ (ឆ្នាំ២០០០) ដែលជាការសិក្សាមួយទៅលើផលប៉ះពាល់មកលើខ្សែទឹកខាងក្រោមដែលបណ្ដាលមកពីទំនប់យ៉ាលី នៅអាងទឹកទន្លេសេសាន នៅក្នុងខេត្តរតនគីរីនៅភាគឦសាននៃប្រទេសកម្ពុជា ។




ទិដ្ឋភាពទន្លេរាក់នៅពេលមិនទំនប់ Yali

ដោយគ្មានការធ្វើវិភាគផលប៉ះពាល់បរិស្ថានឬពិគ្រោះយោបល់ជាមួយប្រជាជនកម្ពុជានៅខ្សែទឹកក្រោមឡើយ ។

អ្នកអានទស្សនាវដ្តី **ការអភិវឌ្ឍន៍ថ្ងៃនេះ** អាចនៅចងចាំថា អ្នកជំនាញការប្រទេសស៊ុយអែត និងណ័រវេស៍មួយក្រុមដែលដឹកនាំដោយ SWECO ត្រូវបានប្រគល់ភារៈកិច្ចនៅឆ្នាំ២០០៣ ដើម្បីសិក្សា EIAs នៃទំនប់ដែលត្រូវបានកសាងឬស្ថិតក្នុងផែនការកសាងនៅលើទន្លេជិតគ្នាពីរនេះ ។ SIDA និង NORAD បានផ្តល់ថវិកាចំពោះ EIA សំរាប់សមាសភាគទន្លេស្រែពក ។ សំរាប់ប្រជាជនកម្ពុជាវិញ អ្នកជំនាញរបស់ Nordic នេះមានសារៈសំខាន់ណាស់ដោយហេតុថា យើងគ្មានទាំងទំនប់ធំៗនៅប្រទេសកម្ពុជា ហើយយើងក៏មិនមានជំនាញដូចនេះដើម្បីដោះស្រាយចំពោះផលប៉ះពាល់របស់វាឡើយ ។

នៅពេលនេះ អ្នកជំនាញការប្រទេស Nordic បានរៀបចំសេចក្តីព្រាងរបាយការណ៍ EIA រួចហើយ ហើយយើងចង់ធានាអោយរបាយការណ៍ទាំងនេះផ្សព្វផ្សាយជាសាធារណៈនៅប្រទេសកម្ពុជាជាមុនសិន ដោយហេតុថាទីនេះហើយជាកន្លែងដែលផលប៉ះពាល់ធ្ងន់ធ្ងរបំផុតបានកើតឡើងច្រើនបំផុតបណ្តាលមកពីទំនប់ដែលបានកសាងនៅខ្សែទឹកខាងលើក្នុងប្រទេសវៀតណាម ។ ទន្ទឹមនឹងនេះ យើងក៏ចង់អោយអ្នកភូមិដែលរងផលប៉ះពាល់ដោយសារទំនប់មានឱកាសពិនិត្យមើលលើអនុសាសន៍របស់អ្នកជំនាញការ Nordic មុនពេលដាក់ស្នើទៅប្រទេសវៀតណាម ។ សូម្បីតែរដ្ឋាភិបាលកម្ពុជាក៏មិនទាន់មានឱកាសពិនិត្យមើលសេចក្តីព្រាង EIAs ទាំងនេះនៅឡើយដែរ ។

យើងមានការព្រួយបារម្ភថា បើសិនគ្មានការត្រួតពិនិត្យជាសាធារណៈនៅប្រទេសកម្ពុជាទេ បញ្ហាសំខាន់ៗដែលត្រូវបានលើកឡើងដោយអ្នកភូមិរងផលប៉ះពាល់ដោយសារទំនប់អាចបាត់បង់នៅក្នុងរបាយការណ៍ចុងក្រោយដែលនឹងដាក់ស្នើទៅអគ្គិសនីវៀតណាម ។ រហូតមកដល់ពេលនេះ អ្នកភូមិមានការលំបាកយ៉ាងខ្លាំងក្នុងការប្រាប់ពីកង្វល់របស់គេទៅប្រទេសវៀតណាម ។ លើសពីនេះទៅទៀត អ្នកជំនាញការ Nordic ធ្វើការអោយប្រទេសវៀតណាមមិនមែនប្រទេសកម្ពុជាទេ ។

អ្នកភូមិនៅទន្លេសេសានដែលបានទទួលរងផលប៉ះពាល់អស់រយៈពេល ១ ទសវត្សមកហើយ ដោយគ្មានសំណង ហើយអ្នកជិតខាងរបស់គេនៅតាមបណ្តោយទន្លេស្រែពក ដែលចង់ដឹងអំពីអ្វីដែលនឹងកើតឡើងជាមួយនឹងទំនប់នៅពេលអនាគតមានសិទ្ធិដឹងពីអ្វីដែលអ្នកជំនាញការរបស់ Nordic នឹងស្នើទៅអតិថិជនរបស់ពួកគេ ពោលគឺអគ្គិសនីវៀតណាម ។

ជាអកុសល សិទ្ធិទាំងនោះមិនត្រូវបានគោរព ឬសូម្បីតែទទួលស្គាល់ដោយ Sida, NORAD និងអ្នកជំនាញវារីអគ្គិសនីរបស់ខ្លួន ។ បើទោះបីជាអ្នកភូមិនៅទន្លេសេសានបានប្តឹងទាមទារសំណងចំពោះការខូចខាតដែលបណ្តាលមកពីទំនប់យ៉ាលីក៏ដោយក៏ Sida និង NORAD នៅតែផ្តល់ថវិកាដោយស្ងាត់ៗទៅដល់ផែនការទាំងឡាយសំរាប់កសាងទំនប់បន្ថែមទៀតនៅតាមបណ្តោយទន្លេសេសាន និងស្រែពកដោយគ្មានការធានាជាបឋមថាផលប៉ះពាល់សង្គមនិងបរិស្ថាននៅខ្សែទឹកខាងក្រោមត្រូវបានដោះស្រាយដោយសមស្រប ឬថាប្រជាជនដែលរងផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជាត្រូវបានពិគ្រោះយោបល់ឡើយ ។ ផែនការនេះមានឈ្មោះថា ផែនការវារីអគ្គិសនីជាតិវៀតណាម ហើយវាត្រូវបានរៀបចំដោយ SWECO និង Statkraft Groner នៅចន្លោះឆ្នាំ១៩៩៩ និង ២០០២ ។

នៅពេលនេះ SWECO កំពុងដឹកនាំការងារ EIA សំរាប់អគ្គិសនីវៀតណាមដែលបានធ្វើអោយយើងមានការព្រួយបារម្ភអំពីទំនាស់ផលប្រយោជន៍។ SWECO ក៏ជាអ្នកជំនាញធំ ដែលកំពុងជួយអគ្គិសនីវៀតណាមរៀបចំផែនការកសាងទំនប់នៅតាមបណ្តោយទន្លេស្រែពកនៅក្នុងតំណាក់កាលទី២ នៃគំរោងការវារីអគ្គិសនីជាតិ NHP ដែលផ្តល់ថវិកាដោយ Sida និង NORAD ផងដែរ។ ដោយមិនគួរអោយជឿ SWECO នេះហើយដែលពីដំបូងជាអ្នកប្រាប់អគ្គិសនីវៀតណាមថា ផលប៉ះពាល់នៅខ្សែទឹកក្រោមដែលបណ្តាលមកពីទំនប់ទន្លេសេសាន នឹងមានកំរិតតូចតាច ហើយមានគ្រួសារកម្ពុជាតែពីរបីគ្រួសារប៉ុណ្ណោះដែលនឹងប៉ះពាល់។

ការសិក្សាក្រោយមួយទៀត ដែលផ្តល់ភារកិច្ចដោយធនាគារអភិវឌ្ឍន៍អាស៊ីបានប៉ាន់ស្មានថា មានគ្រួសារប្រមាណ ២៥០០ ដែលមានសិទ្ធិទាមទារសំណងចំពោះការបាត់បង់ជីវិត និងការខូចខាតទ្រព្យសម្បត្តិដោយសារទំនប់យ៉ាលី ហើយ SWECO បានខកខានមិនបានជូនពត៌មានដល់ម្ចាស់ទំនប់អំពីគ្រោះថ្នាក់លើសុវត្ថិភាពដែលអាចកើតមានឡើងពាក់ព័ន្ធនឹងផែនការប្រតិបត្តិការទំនប់យ៉ាលី។

នៅពេលដែលប្រជាជនកម្ពុជាស្នើសុំអោយ Sida និងNORAD បញ្ឈប់ការផ្តល់ថវិកាចំពោះផែនការវារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម យ៉ាងហោចណាស់រហូតទាល់តែបញ្ហាទន្លេសេសានត្រូវបានដោះស្រាយបាន និងផ្តល់សំណងសមស្របដល់ជនរងគ្រោះសិន ទើប Sida និង NORAD អនុម័តយល់ព្រមលើដំណាក់កាលទីពីរនៃ NHP វៀតណាមដែលនៅពេលនេះមានការបន្ថែម EIA សំរាប់ទន្លេស្រែពក។

ផ្អែកលើប្រវត្តិនៃការមិនអើពើនេះ យើងស្វាគមន៍យ៉ាងខ្លាំងចំពោះការឆ្លើយតបជាវិជ្ជមានពី Sida និង NORAD ដើម្បីរៀបចំសិក្ខាសាលាត្រួតពិនិត្យលើ EIA នៅប្រទេសកម្ពុជា។ យើងសូមស្នើអោយ Sida និង NORAD គោរពទៅតាមគោលបំណងរបស់យើងក្នុងការត្រួតពិនិត្យ EIAs ទាំងពីរ បើទោះបីជា Sida បានចង្អុលបង្ហាញថាខ្លួនបានផ្តល់ថវិកាចំពោះតែការត្រួតពិនិត្យ EIA របស់ស្រែពកក៏ដោយ។ យើងសូមស្នើអោយភ្នាក់ងារទាំងអស់ទទួលស្គាល់នូវការលំបាករបស់អ្នកភូមិដែលរងផលប៉ះពាល់ដោយបញ្ចុះបញ្ចូលរដ្ឋាភិបាលរបស់ពួកគេ និងអគ្គិសនីវៀតណាមអោយស្វែងរកដំណោះស្រាយ។ ការពិគ្រោះយោបល់ជាសាធារណៈត្រឹមត្រូវ និងយុត្តិធម៌សំរាប់សហគមន៍ដែលរងផលប៉ះពាល់ នឹងអាចកើតមានឡើងតែនៅពេលណាដែលភ្នាក់ងារទាំងអស់ដែលគាំទ្រគំរោងកសាងវារីអគ្គិសនីទទួចស្នើសុំអោយអតិថិជនរបស់ពួកគេគោរពទៅតាមស្តង់ដាដែលត្រូវបានគេទទួលស្គាល់ និងគោរពទៅតាមស្តង់ដាដោយពួកគេផ្ទាល់ផងដែរ។

*អត្ថបទដោយលោក **ឈិត សំអាត** នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។*

*អត្ថបទនេះត្រូវបានចុះផ្សាយដំបូងនៅក្នុង Development Today លេខ ៩ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦។*



ជនរងគ្រោះដោយសារគុណភាពទឹករបស់ទន្លេសេសាន

# ផលប៉ះពាល់ពីបញ្ហាព្រៃឈើ ដីធ្លីជនជាតិដើមភាគតិច និងបរិស្ថាននៅខេត្តព្រះវិហារ

កាលពីថ្ងៃទី២៦-៣០ខែមេសាឆ្នាំ២០០៦ ក្រុមអង្គការបណ្តាញព្រៃឈើ និងចំការឈើដាំសហការជាមួយកាសែតកោះសន្តិភាព កាសែត Cambodge Soir វិទ្យុ៩៦ វិទ្យុរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CHHR) និងបណ្តាញអង្គការនៅក្នុងខេត្តព្រះវិហារបានចុះប្រមូលព័ត៌មាននៅភូមិក្រាំងដូង ឃុំព្រះឃ្លាំង ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។

តាមការជួបជាមួយអ្នកភូមិអន្លង់ស្វាយបានអោយដឹងថាមានមន្ត្រីរដ្ឋបាលព្រៃឈើសហការជាមួយប៉ូលីស និងទាហានដែលប្រដាប់ដោយកាំភ្លើងបានអោយអ្នកភូមិកាប់ដើមច្បោះលក់អោយពួកគេ ។ លើសពីនេះទៅទៀតមានរបាយការណ៍មកពីភូមិក្រាំងដូងថា មានទាហាននៅវាលរំពុកបានរំលោភយកដីព្រៃជនជាតិគួយដើម្បីឈូសឆាយលក់ អោយក្រុមហ៊ុនចំការឈើដាំស៊ុយកេតដើម្បីដាំអាកាស្យា ។ ជាពិសេសនៅពេលថ្មីៗនេះមានទាហាននៅភូមិក្រាំងដូងបានបន្តការទន្ទ្រានយកដី ១,១០០ ហិកតាដែលជាដីជនជាតិគួយដែលធ្លាប់ប្រើប្រាស់ធ្វើស្រែចំការ ។

ជនជាតិគួយត្រូវបានគេគំរាមកំហែងបំភិតបំភ័យមិនអោយធ្វើពាក្យបណ្តឹង ។ ចំណែកឯអ្នកភូមិត្រូវបានគេគំរាមកំហែង និងមិនអនុញ្ញាតអោយមានការប្រជុំពិភាក្សាពីបញ្ហាព្រៃឈើឡើយ ។ អ្នកភូមិមានការភ័យខ្លាចចំពោះការបាត់បង់គោ ក្របី មាន់ ទា ដែលត្រូវបានគេលួចរៀងរាល់យប់ ។

តំណាងសហគមន៍ម្នាក់ជាអនុប្រធានសហគមន៍ព្រៃឈើនៅភូមិក្រាំងដូងបានអោយដឹងថាមានការកាប់ដើមច្បោះរបស់ជនជាតិអស់ជាង ៥០ ដើម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ពីសំណាក់ទាហានកងពលលេខ ១២ វរៈសេនាតូច ១២១ ជាហេតុធ្វើអោយប្រជាពលរដ្ឋទាំងអស់មានការព្រួយបារម្ភយ៉ាងខ្លាំងព្រោះការកាប់បំផ្លាញដើមច្បោះ វាពាក់ព័ន្ធនឹងសេដ្ឋកិច្ចជីវភាពព្រោះថាពួកគាត់រកស៊ីធ្វើចន្លុះ ដងជ័រ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារក្រៅពីការធ្វើស្រែចំការ ។ នៅក្នុងភូមិនេះមានប្រជាពលរដ្ឋខ្លះត្រូវបានគេកាប់ដើមច្បោះរបស់ពួកគាត់ស្ទើរតែទាំងអស់ ហើយខ្លះអស់រលីង ដែលធ្វើអោយអ្នកខ្លះមានការយំស្រែក ពីព្រោះដើមច្បោះជាឆ្នាំងបាយរបស់ប្រជាពលរដ្ឋ។ មិនតែប៉ុណ្ណោះនៅពេលដែលម្ចាស់ច្បោះទៅទាន់ពេលកំពុងតែកាប់ ហើយប្រជាពលរដ្ឋនាំគ្នាឃាត់ថាកុំកាប់ដើមច្បោះរបស់ពួកគាត់ ជនទុច្ចរិតឆ្លើយទៅប្រជាពលរដ្ឋវិញថា គេមិនបានកាប់ដល់រណ្តៅច្បោះទេ គឺកាប់ពីលើរណ្តៅច្បោះ ។ ប្រជាពលរដ្ឋមិនហានតវ៉ាអ្វីខ្លាំងទេ ព្រោះពួកអ្នកកាប់សុទ្ធតែមានកាំភ្លើង និងមានអ្នកមានអំណាចឈរពីក្រោយខ្នង ។

ថ្មីៗនេះក៏ដូចជាតាំងពីឆ្នាំមុនៗមកដែរមានការលួចកាប់ឈើប្រណិតដូចជាឈើបេង នាងនួន... ពីសំណាក់ប្រជាពលរដ្ឋមួយចំនួនតូច មិនតែប៉ុណ្ណោះមាននាំចូលនូវម៉ាស៊ីនអារឈើ ២ គ្រឿងដោយមានការអនុញ្ញាតពីទាហាន ឬប៉ូលីស ។

តំណាងសហគមន៍ម្នាក់និយាយពីការលំបាករបស់ពួកគាត់ព្រោះថារយៈពេល៣ឆ្នាំហើយដែលសហគមន៍របស់គាត់បានបង្កើតឡើងតែមិនទាន់មានការទទួលស្គាល់ដូចឃុំផ្សេងៗទៀតនៅឡើយ គឺបណ្តាលមកពីមេប៉ុស្តិ៍ មេឃុំត្រូវគ្នាមិនអោយមានការទទួលស្គាល់សហគមន៍ព្រៃឈើ ។ តំណាងសហគមន៍បន្តទៀតថា រាល់ថ្ងៃនេះប្រជាពលរដ្ឋមានការភ័យខ្លាចយ៉ាងខ្លាំងព្រោះកាលពីឆ្នាំ២០០៥ សមាជិកសហគមន៍ម្នាក់ត្រូវបានប្រជាពលរដ្ឋដូចគ្នាបាញ់



ការកាប់បំផ្លាញព្រៃឈើអនាធិបតេយ្យ



សកម្មភាពឈូសឆាយព្រៃធម្មជាតិដោយក្រុមហ៊ុន

ចំដើមទ្រូងដោយសារគាត់បាននិយាយហាមឃាត់មិនអោយបរបាញ់សត្វព្រៃ និងនិយាយពីរឿងព្រៃឈើ ។

នៅឃុំព្រះឃ្លាំង ប្រជាពលរដ្ឋមួយចំនួនមានកាំភ្លើងដើរបរបាញ់សត្វព្រៃយ៉ាងអនាធិបតេយ្យ និងធ្វើការគំរាមកំហែងដល់ជនណាដែលហ៊ានឈឺឆ្អាលពីរឿងកាប់ព្រៃឈើ ការរុករានយកដីធ្វើចំការ ដោយមានការផ្តល់កាំភ្លើងពីមេប៉ុស្តិ៍ ។

ជាក់ស្តែងអ្នកស្រី លឿន អ៊ីម ជាអនុប្រធានសហគមន៍ម្នាក់មានការភិតភ័យខ្លាំងណាស់ដែរ ព្រោះនៅពេលដែលមានការប្រជុំសហគមន៍ឬមានអង្គការណាចុះជួយរឿងសហគមន៍ តែងតែមានគេទៅគំរាមកំហែងដល់ផ្ទះគាត់នៅពេលយប់ពីសំណាក់ជនមិនស្គាល់មុខ មិនតែប៉ុណ្ណោះនៅតាមផ្លូវជាញឹកញាប់ គាត់បានឮគេនិយាយថា កុំខ្លាំងពេក កុំចេះដឹងពេក ប្រយ័ត្នក្បាលដេកដី ។ អ្នកមីងបន្តថា នៅភូមិអន្លង់ស្វាយមានម៉ាស៊ីនអារឈើ ១០ គ្រឿង ម៉ាស៊ីនឆក់ ១០ គ្រឿង ឧបករណ៍ទាំងនេះជារបស់ប្រជាពលរដ្ឋខ្លះ និងអ្នកចំណូល ស្រុកខ្លះមកពីស្រុករវៀង ដោយមានការអនុញ្ញាតពីមេប៉ុស្តិ៍ ។ ការកាប់ឈើទាំងនេះគេប្រមូលដឹកតាមគោយន្តមកដាក់មួយកន្លែងក្រោយមកទើបគេដឹកចេញ ហើយរដ្ឋបាលព្រៃឈើ និងអាជ្ញាធរបានឃើញក៏គ្មានការទប់ស្កាត់អ្វីដែរ ព្រោះគេបានបង់លុយទៅអោយពួកមន្ត្រីរួចហើយ ។

រដ្ឋបាលព្រៃឈើមិនបានចាត់វិធានការទប់ស្កាត់បទល្មើសព្រៃឈើឡើយ ពួកគេគ្រាន់តែដើរផាកពិន័យអ្នកមានម៉ាស៊ីនអារឈើយកលុយដាក់ហោប៉ៅ ដោយឈើប្រណិតក្នុងមួយម៉ែត្រត្រីគុណ ៨០០០០ រៀល (៨ ម៉ឺនរៀល) ហើយបើឈើធម្មតាក្នុងមួយម៉ែត្រ ៤០០០០ រៀល (៤ ម៉ឺនរៀល) ។

ចំណែកឯរឿងស្ថេរភាពសង្គមវិញប្រជាពលរដ្ឋបានបញ្ជាក់ថាកាលពីឆ្នាំ២០០៤ និង ២០០៥ មានការបាត់គោ ក្របី របស់ប្រជាពលរដ្ឋក្នុងមួយឆ្នាំៗប្រហែល ៥០ ទៅ ៦០ ក្បាល ។ ក្នុងឆ្នាំ២០០៦ ប្រជាពលរដ្ឋសង្កេតឃើញមិនទាន់មានការបាត់បង់គោ ក្របីដូចមុនៗទេ ព្រោះពួកទាហានបានផ្លាស់ពីកន្លែងចាស់ទៅនៅកន្លែងវាលអំពុកវិញ សព្វថ្ងៃបញ្ហាទាំងនេះ ពួកគាត់មានការលំបាកចិត្តយ៉ាងខ្លាំង ព្រោះអ្នកខ្លះត្រូវអស់រលីងគ្មានគោ ក្របីសម្រាប់ធ្វើស្រែចំការ ។

ចំណែកលោក ហ៊ិន ផុត តំណាងសហគមន៍ភូមិក្រាំងដូង និយាយថាមានការរំលោភយកដីធ្លីប្រជាពលរដ្ឋអស់ ១២ គ្រួសារពីសំណាក់ទាហានដែលមកពីជើងភ្នំដងរែក ទាហានមកតាំងទីលំនៅតាំងពីឆ្នាំ២០០២ មិនតែប៉ុណ្ណោះមានការកាប់ដើមច្បោះ កាប់ព្រៃ និងយកថ្មទៅធ្វើព្រះ ។ លោកមេភូមិមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបញ្ហាទាំងនេះ ព្រោះអាចនាំអោយប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋដូចជា គ្មានភ្លៀង អត់ទឹកធ្វើស្រែចំការ អស់អនុផលព្រៃឈើរបស់ពួកគាត់ ។ ភាពអយុត្តិធម៌បានកើតមានច្រើនចំពោះប្រជាពលរដ្ឋ ព្រោះអាជ្ញាធរបានឃាត់ឃាំងពួកគាត់មិនអោយកាប់ព្រៃតូចៗបន្តិចបន្តួចសម្រាប់ធ្វើស្រែចំការទេ តែបានបើកឱកាសឱ្យអ្នកមានលុយកាក់មានអំណាចកាប់សុទ្ធតែឈើធំៗនៅក្នុងដីរបស់ជនជាតិដើមភាគតិចគួយ ។ បើតាមសំដីអះអាងរបស់អ្នកមីង ឈុន ហោម ជនជាតិគួយ បាននិយាយថាអ្នកមីងត្រូវបានទទួលការរំលោភយកដីពីថៅកែម្នាក់មកពីខេត្តកំពង់ចាម ហើយបានរាយការណ៍ទៅឃុំ អោយជួយរកដំណោះស្រាយ ថែមទាំងគេគំរាមរកវាយតប់នៅពេលអ្នកមីងសូមសំណូមពរដល់ខេត្តឱ្យជួយអន្តរាគមន៍រឿងនេះ ។

ប្រជាពលរដ្ឋភាគច្រើនបាននិយាយថាមានការកាប់ច្បោះរបស់ពួកគាត់ពីសំណាក់ទាហាននៃវរៈសេនាតូចលេខ ១២ នៅវាលអំពុកមែន ។ លោក ធឿន ជនជាតិគួយដែលជាអនុប្រធានសហគមន៍ព្រៃឈើនៅភូមិក្រាំងដូង និយាយថាសព្វថ្ងៃនេះមានការកាប់បំផ្លាញព្រៃឈើជាច្រើននៅក្នុងព្រៃជ្រៅៗពីសំណាក់ជនមិនស្គាល់មុខ និងទាហាន មិនតែប៉ុណ្ណោះទាហានបានបណ្តេញក្រុមគ្រួសារលោក ធឿនចេញពីលំនៅដ្ឋាន ដោយយកកន្លែងអោយទាហានស្នាក់នៅដោយគាត់មិនព្រមចេញកាលពីឆ្នាំ២០០៥ ។

អ្នកភូមិក្រាំងដូងបានអោយដឹងថា បច្ចុប្បន្ននេះអ្នកភូមិភាគច្រើនមិនអាចចូលទៅដងជ័រច្បោះបានទៀតឡើយ ដោយច្បោះរបស់ពួកគាត់ត្រូវបានកាប់អស់ពីសំណាក់ទាហាន និងអ្នកមានអំណាច លើសពីនេះទៅទៀតពួកគាត់អាចរកអនុផលព្រៃឈើបានតិចតួច ដោយសារព្រៃឈើដែលមានតាំងពីដូនតាត្រូវបានកាប់បំផ្លាញអស់ ដែលជាហេតុធ្វើអោយជីវភាពរបស់ពួកគាត់មានការលំបាក ។ ពួកគាត់ស្នើសុំអោយរាជរដ្ឋាភិបាល អាជ្ញាធរ និងអង្គការនានាជួយធ្វើអន្តរាគមន៍ចំពោះបញ្ហាទាំងនេះផង ព្រោះថាមានតែព្រៃឈើទេ ដែលជាអាយុជីវិតរបស់ពួកគាត់ធ្លាប់ពឹងអាស្រ័យតាំងពីច្រើនជំនាន់មកហើយ បើព្រៃឈើត្រូវបានកាប់បំផ្លាញអស់ តើពួកគាត់ពឹងលើអ្វីទៀត?

*អត្ថបទដោយអ្នកស្រី* ***ធាន់ សុខុម*** *មន្ត្រីគំរោងព្រៃឈើ និងចំការឈើដាំវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*



ការឈូសឆាយរំលើងព្រៃធម្មជាតិ

# វិធីបំបាក់ស្មារតីដោយការបង្ក្រាប ដោយចោទថាជាបទល្មើសជាក់ស្តែង

ភូមិព្រែកក្តីស្ថិតនៅចំងាយ ៦៥ គីឡូម៉ែត្រ ភាគខាងជើងទីរួមខេត្តក្នុងឃុំស្នួល ស្រុកស្នួល ខេត្តក្រចេះ។ ជនជាតិស្ទៀងមួយគ្រួសារដែលមានសមាជិក ៧ នាក់រស់នៅក្នុងភូមិព្រែកក្តីត្រូវបានគេឃុំខ្លួនច្រើនជាងរយៈមួយខែ កាលពីដើមខែកុម្ភៈ ឆ្នាំ២០០៦។ លោក ជួន ចាន់ដាច់ អាយុ ៥១ ឆ្នាំ ប្រពន្ធឈ្មោះ ផុន សារុន អាយុ ៤៧ ឆ្នាំ និងកូនប្រុសរបស់គាត់អាយុ ១៥ ឆ្នាំជាមួយកូនប្រសារប្រុសត្រូវបានចាប់ខ្លួនពីបទចោទប្រកាន់ថាបានកាប់ឆ្ការព្រៃឈើដោយខុសច្បាប់នៅពេលដែលមជ្ឈដ្ឋានទូទៅកំពុងរង់ចាំមើលថាតើករណីជាច្រើនដែលប្រព្រឹត្តបទល្មើសព្រៃឈើដោយអ្នកធំៗកំពុងមានសុវត្ថិភាព។

អ្នកភូមិខាងលើបានចាប់ផ្តើមកាប់ឆ្ការព្រៃនៅក្បែរតំបន់ក្រុមហ៊ុនចំការអាកាស្យាដែលជាកម្មសិទ្ធិរបស់លោក "ក" និងអ្នកស្រី "ខ" ដែលកាលពីមុនឈ្មោះ ជុន ចាន់ដាច់ បានធ្វើការស្នើសុំដីទំហំ ៦០,១០០ ម៉ែត្រ សំរាប់ធ្វើការដាំដំណាំ។ ស្រាប់តែពេលនោះ មានរដ្ឋបាលព្រៃឈើរួមជាមួយកងរាជអាវុធហត្ថចំនួន ៤ នាក់ ប្រដាប់ដោយអាវុធបានធ្វើការឃាត់ខ្លួនពួកគេ ហើយបញ្ជូនខ្លួនទៅតុលាការភ្លាមៗបន្ទាប់ពីបានធ្វើការសាកសួរ និងធ្វើកំណត់ហេតុរួច។ ដោយសារហេតុការណ៍នេះហាក់បីដូចជាមានការរៀបចំគំរោងការទុកជាមុន ជាហេតុធ្វើឱ្យអ្នកភូមិទាំងមូលមានការភ្ញាក់ផ្អើល និងនាំគ្នាស្វែងរកការគាំទ្រភ្លាមៗដែរ។ ពួកគេបានចូលរួមធ្វើលិខិតដើម្បីផ្ញើជូនអភិបាលខេត្ត និងតុលាការ ដើម្បីសុំបង់ប្រាក់ធានាអោយនៅក្រៅឃុំ។ លិខិតដែលប្រកបដោយសេចក្តីអង្វរបានបញ្ជាក់ថាពួកគេពុំមានបំណងបំផ្លាញព្រៃឈើទេ គឺគ្រួសារនេះជាអ្នកខ្វះខាតដីធ្លីនៅក្នុងភូមិ។ លិខិតនេះត្រូវបានធ្វើឡើងនៅថ្ងៃទី ៨ ខែកុម្ភៈ គឺក្រោយការចាប់ខ្លួន ១ ថ្ងៃ ប៉ុន្តែពុំមានការឆ្លើយតបអ្វីទេពីសំណាក់អាជ្ញាធរស្តីពីបញ្ហានេះ។ នៅថ្ងៃទី ១០ ខែដដែលអ្នកភូមិបានចូលរួមធ្វើលិខិតគាំទ្រគ្រួសារដែលត្រូវបានចាប់ខ្លួន ដើម្បីអោយពួកគេអាចនៅក្រៅឃុំព្រមទាំងកូនប្រុសដែលមានអាយុ ១៥ ឆ្នាំត្រឡប់ទៅសាលារៀនបាន។

*ការស្វែងរកករណីបន្តបន្ទាប់ និងមូលហេតុពិតប្រាកដទាំងនេះគឺជាអ្វី ?*

លោក ជុន ចាន់ដាច់ បានបង្កើតស្នាដៃសំរាប់សហគមន៍ព្រៃឈើជាច្រើនក្នុងអំឡុងកាលនៃបេសកកម្មរបស់គាត់ក្នុងការការពារ និងយាមល្បាតជាមួយសហការីក្នុងការទប់ស្កាត់ការកាប់ឈើខុសច្បាប់ដែលមានការទាក់ទិននឹងបុគ្គលអ្នកមានអំណាចនៅក្នុងតំបន់។ ការតស៊ូជាមួយអាជ្ញាធរក្នុងរឿងដីធ្លី និងព្រៃឈើមិនមែនជាបរិបទសមស្របសំរាប់បច្ចុប្បន្នភាពនេះឡើយ។

ជីវិតដ៏សាំញ៉ាំរបស់គាត់ ប្រពន្ធគាត់ និងកូនប្រសារប្រុសរបស់គាត់នៅក្នុងពន្ធនាគារ គឺជាមេរៀនដ៏សែនអប្រិយ៍សំរាប់សកម្មជនដទៃទៀត។ អ្វីដែលគួរឱ្យសន្និដ្ឋានបានថា វាជាការរៀបចំទុកជាមុននោះ គឺដោយសារតែក្នុងកំឡុងចុងឆ្នាំ២០០៥ និងដើមឆ្នាំ២០០៦ មានករណីស្រដៀងគ្នាកើតឡើងស្ទើរគ្រប់តំបន់ដែលមានវិវាទដីធ្លី ហើយសហគមន៍ ឬសកម្មជនទាំងនោះតែងតែទទួលបាននូវការធ្វើទុក្ខបុកម្នេញដោយការគំរាមបំភិតបំភ័យ ការបង្កររឿងរ៉ាវ ការឃុំខ្លួន។ល។ ចំពោះគ្រួសារ និងមិត្តភក្តិរបស់គេគឺទទួលបានទឹកភ្នែក និងភាពភ័យខ្លាច។



តំបន់ព្រៃដែលរងការកាប់បំផ្លាញដោយអ្នកមានអំណាចដែលមានទំហំធំៗ ក្នុងស្រុកស្នួល ខេត្តក្រចេះ ដែលមិនមានការចាប់អារម្មណ៍ពីសំណាក់អាជ្ញាធរ



## ១.ករណីដីធ្លី:

អ្នកភូមិព្រែកក្ដីបានកាន់កាប់ដីពី ១-៣ ហិកតា ក្នុងមួយគ្រួសារសំរាប់ធ្វើកសិកម្ម ។ កាលពីមុន មានអ្នកភូមិចំនួនដប់គ្រួសារបានលក់ដីទៅអោយអ្នកខាងក្រៅដែលមានទំហំប្រមាណ ២៥ ហិកតា ហើយសុទ្ធសឹងតែសំរាប់សាងសង់លំនៅដ្ឋាន និងកសិកម្ម ។ ក៏ប៉ុន្តែគ្រួសារលោក ជុន ចាន់ដាច់ ពុំបានលក់ទេ ហើយគាត់មានដីចំនួន ៦,០០០ ម៉ែត្រការ៉េ នៅក្នុងឃុំស្នួល ។ អ្នកភូមិបានលើកឡើងថា ភាគច្រើននៃដីនៅជុំវិញតំបន់នេះ គឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុនបុគ្គលអ្នកមាន និងអ្នកមានអំណាចដែលក្នុងនោះដីទំហំ ១០០ ហិកតា គឺជាកម្មសិទ្ធិរបស់អភិបាលខេត្ត ហើយក្រៅពីនេះដីប្រហែល ១០ គីឡូម៉ែត្រការ៉េជាកម្មសិទ្ធិរបស់អភិបាលស្រុក មេឃុំ និងកងរាជអាវុធហត្ថ ។

ដីទំហំរាប់រយហិកតាផ្សេងទៀត គឺជារបស់ក្រុមហ៊ុនចំនួនពីរគឺ ក្រុមហ៊ុន CEPA និងមួយទៀតមិនស្គាល់ឈ្មោះ ។ ដីទំហំ ៦០ ហិកតា ជាកម្មសិទ្ធិរបស់ក្រុមហ៊ុនចំការអាកាស្យាតាំងពីឆ្នាំ២០០៤មក ហើយគ្រប់គ្រងដោយលោក ឌុល រ៉ា និងម្ចាស់ពិតប្រាកដរស់នៅភ្នំពេញដែលអ្នកភូមិពុំបានស្គាល់ឈ្មោះដែរ ។

## ២.ករណីព្រៃឈើ:

ការកាប់ឆ្ការព្រៃឈើបានកើនឡើងយ៉ាងខ្លាំងបន្ទាប់ពី ជុន ចាន់ ដាច់ត្រូវបានចាប់ខ្លួន ។ ការកាប់ឈើខុសច្បាប់អាចធ្វើឡើងដោយសេរីមិនថាជាពេលយប់ ឬថ្ងៃ ។ ក្នុងរយៈពេលនេះដែរ ជនជាតិខ្មែរអ៊ីស្លាមដែលចូលមកតាំងទីលំនៅថ្មីបានជួលអ្នកភូមិអោយកាប់ឆ្ការព្រៃក្នុងតំលៃ ២០០,០០០ រៀលក្នុងមួយហិកតា ឬ ៥,០០០រៀល ក្នុងមួយថ្ងៃ ។ តាមរយៈការសាកសួរអ្នកភូមិបានអោយដឹងថា គ្មានរដ្ឋបាលព្រៃឈើកងរាជអាវុធហត្ថ អាជ្ញាធរណាមួយធ្វើអន្តរាគមន៍លើករណីនេះទេ ។

នៅអមសងខាងផ្លូវពីស្នួលទៅក្រចេះជាពិសេសតំបន់ការពារព្រៃឈើត្រូវបានកាប់បំផ្លាញ រដ្ឋបាលព្រៃឈើខ្សឹមបានអោយដឹងថា ពួកគេបានមកកាប់នៅពេលយប់ដូច្នេះអាជ្ញាធរពុំអាចទប់ស្កាត់បានទេ ។ មានបញ្ហាថ្មី ដែលទើបនឹងកើតឡើងនោះគឺការចាប់សត្វស្វាដោយប្រើអង្គប់ ហើយបញ្ជូនទៅលក់នៅប្រទេសវៀតណាម ។ តាមអ្នកភូមិបាននៅទីនោះ បានអោយដឹងថា ករណីនេះទើបតែកើតឡើងក្នុងអំឡុងខែមុននេះទេ ។

នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០០៥ ជុន ចាន់ដាច់ និងលោកស្រី សឿន សារឿន ត្រូវបានគំរាមកំហែងដោយកងរាជអាវុធហត្ថ, រដ្ឋបាលព្រៃឈើ និងអភិបាលស្រុក ។ បញ្ហាពាក់ព័ន្ធគឺជាប់ទាក់ទងនឹងក្រុមកាប់ឈើខុសច្បាប់ដោយរណារយន្ត និងបញ្ហាផ្សេងៗទៀត អ្នកកាប់ឈើទាំងនោះគឺជាសាច់ញាតិនៃអាជ្ញាធរមូលដ្ឋាន ។ បន្ទាប់ពីការគំរាមកំហែងខាងលើមកទល់ថ្ងៃ ២៩ ខែធ្នូ ឆ្នាំ២០០៥ លោកមេឃុំស្នួលបានចេញដីកាមួយលែងទទួលស្គាល់លោក ចាន់ដាច់ និងអ្នកស្រី សឿន សារឿន ដោយព្រមានពួកគេមិនអនុញ្ញាតអោយចូលរួមសកម្មភាពផ្សេងៗទាក់ទងនឹងសហគមន៍ព្រៃឈើ ។ បន្ទាប់ពីលោក ចាន់ដាច់ ត្រូវចាប់ខ្លួនជាមួយគ្រួសារគាត់មានជនចំលែក (មិនអាចប្រាប់ឈ្មោះ) ចូលមកក្នុងភូមិទាំងស្រវឹងដោយកាន់ដបស្រាហើយសើចចំអកអោយអ្នកភូមិ ជាពិសេសចំអកអោយអ្នកដែលធ្លាប់ធ្វើការជាមួយលោក ចាន់ដាច់ និង លោកស្រី សឿន សារឿន ជាដៃគូដ៏ជិតស្និទ្ធជាមួយលោក ចាន់ដាច់កំពុងត្រូវបានគំរាមកំហែងជាមួយនឹងករណីស្រដៀងគ្នានឹងចាន់ដាច់ដែរ ។ ទោះបីជាយ៉ាងណាក៏ដោយក៏សមាជិកនៃគណៈកម្មការសហគមន៍ព្រៃឈើទាំងអស់បានទទួលរងនូវការគំរាមកំហែងផងដែរ

ហើយមកទល់បច្ចុប្បន្នពួកគេទាំងអស់បានបែកខ្ញែកគ្នា ហើយខ្លះការតាំងចិត្ត ដើម្បីបន្តការងាររបស់ពួកគេទៀត ។ មនុស្សទាំងនេះកំពុងទទួលរងនូវការស៊ើបអង្កេតពីសំណាក់អាជ្ញាធរមូលដ្ឋានទៅលើរាល់សកម្មភាពរួមទាំងកិច្ចការពារធនធានធម្មជាតិ និងការចូលរួមផ្សេងៗជាមួយ NGOs និងបុគ្គលិកសង្គមស៊ីវិល ។

ម្យ៉ាងវិញទៀតតំបន់ភាគខាងកើត និងខាងជើងនៃភូមិនេះប្រហែល ៣០០ ម៉ែត្រ មានគំនរកាកសំណល់សំរាមយ៉ាងច្រើន ធ្វើអោយប៉ះពាល់ដល់ក្មេងៗដែលលេង និងគោក្របីដែលស៊ីស្មៅនៅក្នុងតំបន់នេះ ។ កាកសំណល់សំរាមទាំងនេះត្រូវបានគេដឹកមកពីផ្សារស្រុកស្នួល យកមកចាក់ចោលនៅក្បែរភូមិ ហើយគំរាមមិនអោយអ្នកភូមិតវ៉ាទេ ។ ករណីនេះគឺត្រូវបានយល់ព្រមរវាងអាជ្ញាធរមូលដ្ឋាន និងអ្នកគ្រប់គ្រងផ្សារ ។ នៅពេលដែលខ្យល់បក់ចូលមកបាននាំក្លិនអាក្រក់ចូលទៅក្នុងភូមិ ហើយធ្វើអោយប៉ះពាល់ដល់សុខភាពប្រជាជន ។

ក្រុមស៊ើបអង្កេត និងអ្នកសារព័ត៌មានបានចុះទៅដល់តំបន់មានជំលោះនៅថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០០៦ និងបានធ្វើការចុះប្រមូលព័ត៌មាន និងភស្តុតាង ។ យើងបានរកឃើញថា មានផ្ទៃដីដាំអាកាស្យាដ៏ធំដែលមានទំហំធំជាង ៥០ ហិកតា ដែលបានដាំតាំងពីឆ្នាំ២០០៤ មកម្លេះ ។ នៅកន្លែងកើតហេតុ យើងបានប្រទះឃើញសញ្ញាសំគាល់ដែលសរសេរថា "ដីមានម្ចាស់ឆ្នាំ ១៩៩៩" ។ សញ្ញាសំគាល់នេះ គឺនៅតាមបណ្តោយព្រំប្រទល់ចំការអាកាស្យា និងតំបន់ដែល លោក ចាន់ដាច់ បានកាប់ឆ្ការ ។ នៅផ្នែកខាងស្តាំដៃដីរបស់ លោក ចាន់ដាច់ មានដីដែលបានកាប់ឆ្ការរួចទំហំប្រហែល ៤០ ម៉ែត្រការ៉េ ដែលយើងមិនបានដឹងថាជារបស់អ្នកណា ។ អ្នកភូមិដែលបានរួមដំណើរជាមួយក្រុមការងារបានអោយដឹងថា ដីនេះគឺជារបស់ លោក ចាន់ដាច់ តាំងពីឆ្នាំ១៩៧៩ មកម្លេះ បន្ទាប់មកគាត់បានចូលបំរើកងទ័ពអស់រយៈពេលយូរហើយ តែនៅពេលដែលគាត់បានដឹងថាម្ចាស់ចំការអាកាស្យា លោក ឌុល រ៉ា ចង់បានដីរបស់គាត់ដើម្បីពង្រីកចំការរបស់គេ ដូច្នេះហើយនៅថ្ងៃមួយគាត់បានទៅជួប លោក ឌុល រ៉ា នៅពេលនោះ លោក ឌុល រ៉ា បានស្នើទិញដីរបស់គាត់តែ លោកចាន់ដាច់ ពុំបានយល់ព្រម លោក ឌុល រ៉ា ក៏បានព្រមានថាគាត់ត្រូវតែលក់ដីនោះអោយគេ ព្រោះពុំមានលទ្ធភាពបង់ពន្ធដីទេ ហើយប្រសិនបើគាត់ពុំព្រមទទួលយកលុយ ១០០ ដុល្លាក្នុងមួយហិកតាទេ គាត់នឹងបាត់បង់ដីនោះ ។ ទោះបីជាយ៉ាងណាក៏ លោក ចាន់ដាច់ មិនបានយល់ព្រមអ្វីទាំងអស់ជាមួយ លោក ឌុល រ៉ា ដែលនេះជាហេតុធ្វើអោយគាត់ចាប់ផ្តើមសកម្មភាពផ្សេងៗ ដូចជាកាប់ដើមឈើតូចៗ និងកំណត់ព្រំប្រទល់ដើម្បីប្រឆាំងនឹងបុគ្គលរូបនេះដែលមានអាជ្ញាធរមូលដ្ឋានឈរនៅពីក្រោយខ្នង ។ ទោះបីជាតំបន់ចំការអាកាស្យានេះបានកាប់ដើមឈើហើយខ្លះក៏ដោយ ក៏ក្រុមការងារ និងអ្នកសារព័ត៌មានបានធ្វើដំណើរចូលទៅក្នុងព្រៃដើម្បីទៅមើលកន្លែងផ្សេងដែលត្រូវបានកាប់ឆ្ការ ហើយត្រូវជាកម្មសិទ្ធិរបស់បុគ្គលដែលបានរៀបរាប់ខាងលើ ។ យើងបានកត់សំគាល់ឃើញថា លោក ចាន់ដាច់ បានរស់នៅក្នុងឃុំស្នួល និងតំបន់ដែលនៅព្រមទាំងតំបន់ព្រៃការពារនៅតាមបណ្តោយផ្លូវជាតិលេខ ៧ ហើយ លោក ចាន់ដាច់ មានបណ្តាញធនធានធម្មជាតិជាច្រើននៅក្នុងស្រុកស្នួល ហើយធ្វើការងារតាមរយៈការសំរបសំរួលជាមួយគណៈកម្មាការសហគមន៍ព្រៃឈើដទៃទៀតនៅក្នុងស្រុក ។ ក្នុងអំឡុងខែមករា ឆ្នាំ២០០៦ គណៈកម្មាការសហគមន៍ព្រៃឈើដែលដឹកនាំដោយ លោក ចាន់ដាច់ ដើម្បីល្បាតក្នុងតំបន់គោលដៅ ហើយបានរឹបអូសត្រង់ស៊ីន័ររបស់កូនប្រុសលោក ហេង ប៉ី សមាជិកគណៈកម្មាការស៊ុរិយោដី



ការប្រមូលភស្តុតាងនានាដោយអ្នកចូលរួមក្នុងភូមិព្រៃកក្តី

ស្រុកស្នួល ។ លោក ញ៉ែម សៀ សមាជិកគណៈកម្មាការសហគមន៍ព្រៃឈើដែលតែងតែសហប្រតិបត្តិការជាមួយ លោក ចាន់ដាច់ បាននិយាយថា "ការចាប់ខ្លួននេះ គឺបណ្តាលមកពីគំនុំផ្ទាល់ខ្លួនរវាងគណៈកម្មការស៊ុរិយោដីស្រុកស្នួល និងសហគមន៍ព្រៃឈើរបស់គាត់ដែល លោកចាន់ដាច់ មានការទាក់ទិនយ៉ាងខ្លាំងចំពោះការទប់ស្កាត់បទល្មើសព្រៃឈើក្នុងតំបន់" ។

មេឃុំ ខ្សឹម លោក អ៊ឹម ផន បានផ្តល់ការគាំទ្រតាមរយៈការកត់សំគាល់របស់ខ្ញុំ លោក ចាន់ដាច់ គឺជាមនុស្សល្អដែលយើងគួរកុំរំលឹកអ្វីៗដែលបានកើតឡើងពីមុន ។ ខ្លួនខ្ញុំផ្ទាល់យល់ឃើញថា ករណីនេះកើតឡើងដោយសារអាជ្ញាធរមូលដ្ឋានបានចាប់ផ្តើមស្អប់ លោកចាន់ដាច់ ដែលបានធ្វើឱ្យមានសុវត្ថិភាពដីធ្លី និងព្រៃឈើតាមរយៈសហគមន៍ព្រៃឈើរបស់គាត់ ។ ប្រជាពលរដ្ឋជាច្រើនទៀតក្នុងស្រុកស្នួលបានឱ្យដឹងថា ជួនកាលពួកគេចង់ធ្វើបាតុកម្មដើម្បីប្រឆាំង នឹងអភិបាលស្រុក ។ ចាប់តាំងពីគាត់បានក្លាយជាអភិបាលស្រុកមក មានមនុស្សជាច្រើនត្រូវបានចាប់ដាក់គុកដែលទាក់ទងនឹងករណីដីធ្លី និងព្រៃឈើ ប៉ុន្តែខ្លួនគាត់គឺអ្នកដែលរំលោភ និងមានដីជាច្រើនហិកតានៅក្នុងស្រុកស្នួល ។ ប៉ូលីសម្នាក់នៅក្នុងខេត្តបាននិយាយថា "ខ្ញុំមិនជឿថានេះគឺជាកំហុសរបស់ លោក ចាន់ដាច់ ទេ គឺប្រហែលជានរណាម្នាក់ធ្វើបាបគាត់ច្រើនជាង ដោយសារគេពុំអាចប្រឈមមុខដោយផ្ទាល់ជាមួយគាត់ ។" បុគ្គលិកមជ្ឈមណ្ឌលសិទ្ធិមនុស្សសំរាប់កម្ពុជា (CCHR) ដែលមានទីតាំងស្ថិតក្នុងខេត្តក្រចេះ បានឱ្យដឹងថា តាមរយៈការកត់សំគាល់របស់ខ្ញុំ និងមិត្តភ័ក្រ្តចាស់ៗបានប្រាប់ខ្ញុំថា ពួកគេមានជំលោះផ្ទៃក្នុងជាមួយអ្នកដទៃរវាងរដ្ឋបាលព្រៃឈើ និងតុលាការខេត្ត ដូចនេះហើយទើបករណីព្រៃឈើ និងដីធ្លីមិនដែលត្រូវបានគេនាំយកទៅកាត់ក្តី ជាពិសេសក្នុងឃុំស្នួល ។ ករណីបានជះឥទ្ធិពលទៅលើសហគមន៍មូលដ្ឋាន ហើយបានអូសទាញអោយមានការចូលរួមពីសំណាក់សហគមន៍ សារព័ត៌មាន NGOs និងអ្នកពាក់ព័ន្ធដទៃទៀត ។ វាគឺជាជំលោះដែលប្រឈមមុខនឹងសកម្មជនរបស់សហគមន៍ដែលកំពុងធ្វើការយ៉ាងខ្លាំងក្លាដើម្បីការពារ និងអភិរក្សធនធានធម្មជាតិ តទល់នឹងមន្ត្រីថ្នាក់ខ្ពស់ និងឈ្មួញទុច្ចរិត ។

*អត្ថបទដោយលោក* ***ឯក យុទ្ធិន*** *មន្ត្រីគំរោងសិទ្ធិជនជាតិដើមភាគតិច វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*

# តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងការទប់ស្កាត់អំពើពុករលួយ

តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយមានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកកំពស់អភិបាលកិច្ចល្អ និងត្រួតពិនិត្យអំពើពុករលួយ ។ សារព័ត៌មានមិនត្រឹមតែផ្តល់នូវការយល់ដឹងដល់សាធារណជនអំពីអំពើពុករលួយ ដើមហេតុបច្ច័យនានា និងលទ្ធភាពបង្ការផ្សេងៗប៉ុណ្ណោះទេប៉ុន្តែក៏មានតួនាទីយ៉ាងសំខាន់ក្នុងការស៊ើបអង្កេត និងរាយការណ៍ពីឧប្បត្តិហេតុនៃអំពើពុករលួយផងដែរ ។ ផ្ទុយទៅវិញប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយគឺអាស្រ័យទៅលើពត៌មានដែលទទួលបាន និងសេរីភាពក្នុងការបញ្ចេញមតិ ហើយវាក៏អាស្រ័យផងដែរទៅលើវិជ្ជាជីវៈ និងអ្នកហ៊ឹកហ៊ឺនក្រមសីលធម៌របស់អ្នកសារពត៌មានផ្នែកស៊ើបអង្កេតផងដែរ ។

តើអំពើពុករលួយត្រូវបានគេផ្តល់និយមន័យថាយ៉ាងដូចម្តេច? លោករីកស្តេផេនហ៊ឹស បានអោយនិយមន័យអំពើពុករលួយថា ***"ជាការរំលោភអំណាចសាធារណៈដើម្បីទទួលបាននូវអ្វីមួយសំរាប់បុគ្គលខ្លួនឯង ឬសំរាប់ផលប្រយោជន៍របស់ក្រុមមួយដែលខ្លួនឯងមានសាមីភក្តិចំពោះក្រុមនោះ"*** ។ អំពើពុករលួយកើតឡើងនៅត្រង់ចំណុចប្រសព្វនៃផ្នែកសាធារណៈ និងផ្នែកឯកជន ពោលគឺនៅពេលការិយាល័យសាធារណៈបានបំពានតាមរយៈការទទួលការរ៉ែអង្គាសប្រាក់ ឬការគំរាមកំហែងយកសំណូកជាថ្នូរការ ។ សកម្មភាពនៃអំពើពុករលួយកើតឡើងនៅពេលដែលមានកាលានុវត្តភាព (ឱកាសហុចអោយ) និងមានសញ្ញាដែលអាចប្រព្រឹត្តទៅបាន ។ គ្លីតហ្គាដ រ៉ូប៊ីត បានបង្កើតឡើងនូវគំរូដ៏សាមញ្ញមួយដើម្បីបកស្រាយអំពីថាមពលនៃអំពើពុករលួយដូចខាងក្រោម:

***អំពើពុកសរលួយ = (អំណាចផ្តាច់មុខ + ការសំរេចចិត្តដោយឯកឯង) - (គណនេយ្យភាព)***

គេអាចនិយាយដោយខ្លីថា វិសាលភាពនៃអំពើពុករលួយអាស្រ័យទៅលើចំនួននៃអំណាចផ្តាច់មុខ និងអំណាចក្នុងការធ្វើសេចក្តីសំរេចចិត្តដោយឯកឯងដែលមន្ត្រីម្នាក់អនុវត្ត ។ អំណាចផ្តាច់មុខភាគច្រើនកើតមានសំរាប់ប្រទេសដែលរដ្ឋាភិបាលមានឥទ្ធិពលខ្លាំងលើផ្នែកសេដ្ឋកិច្ច ចំណែកឯអំណាចក្នុងការធ្វើសេចក្តីសំរេចចិត្តច្រើនកើតមាននៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចអន្តរកាល ហើយបទបញ្ជា និងច្បាប់នានាផ្នែករដ្ឋបាលមានលក្ខណៈទន់ខ្សោយ ហើយដែលត្រូវបានញាំញីដោយភាពខ្សោយខាងនីតិរដ្ឋ ។ នៅទីបំផុតគណនេយ្យភាពក៏ខ្សោយទៅតាមនោះដែរ ដោយសារតែភាពខ្សោយក្នុងការកំណត់និយាមសីលធម៌សំរាប់សេវាសាធារណៈ ភាពខ្សោយខាងប្រព័ន្ធហិរញ្ញវត្ថុ និងរដ្ឋបាល និងទីភ្នាក់ងារឃ្លាំមើលដ៏មានប្រសិទ្ធភាព ។

យុទ្ធសាស្ត្រមួយចំនួនដែលឈានទៅរកភាពជោគជ័យក្នុងការទប់ស្កាត់អំពើពុករលួយក្នុងពេលជាមួយគ្នាត្រូវតែខិតខំប្រឹងប្រែងដើម្បីលុបបំបាត់អោយបាននូវអំណាចផ្តាច់មុខរបស់មន្ត្រីណាម្នាក់ (ឧទាហរណ៍តាមរយៈកំណែទំរង់ដោយសង្កត់ធ្ងន់លើផ្នែកទីផ្សារ) លុបបំបាត់ការធ្វើសេចក្តីសំរេចចិត្តដោយឯកឯងរបស់គេ (តាមរយៈកំណែទំរង់រដ្ឋបាល) និងពង្រឹងតម្លាភាពរបស់ពួកគេតាមរយៈទីភ្នាក់ងារឃ្លាំមើល ។

យុទ្ធសាស្ត្រទាំងនេះរួមបញ្ចូលទាំងប្រពន្ធ័ Check and Balance ដែលត្រូវបានរៀបចំឡើងដើម្បីគ្រប់គ្រង ដូច្នេះផលប្រយោជន៍ក្នុងផ្នែកសាធារណៈ និងស្ថានភាពមួយចំនួនកំណត់ ដែលមានជម្លោះផលប្រយោជន៍ ឬមានផលប៉ះពាល់អវិជ្ជមានដល់ផលប្រយោជន៍រួម ។ យុទ្ធសាស្ត្រទាំងនោះមាននៅក្នុងទស្សនៈទូលំទូលាយក្នុងការកែទំរង់ការដោះស្រាយបញ្ហាពុករលួយក្នុងវិស័យសាធារណៈតាមរយៈដំណើរការទាំងឡាយរបស់រដ្ឋាភិបាល (ឧទាហរណ៍ក្រមសីលធម៌សំរាប់អ្នកដឹកនាំការផ្លាស់ប្តូរការរៀបចំ) និងតាមរយៈការចូលរួមរបស់សង្គមស៊ីវិល (ដំណើរការប្រជាធិបតេយ្យវិស័យឯកជន និងប្រពន្ធ័ផ្សព្វផ្សាយ) ។

លោក Kaufmann បានលើកឡើងថា:

***ការខិតខំប្រឹងប្រែងការកាត់បន្ថយអំពើរពុករលួយ = (ចំណេះដឹងនិងពត៌មាន) + (ភាពជាអ្នកដឹកនាំ) + (សកម្មភាពរួម)***

គេអាចនិយាយបានម្យ៉ាងទៀតថា ជោគជ័យក្នុងកម្មវិធីប្រឆាំងអំពើពុករលួយគឺអាស្រ័យលើពត៌មាន និងចំណេះដឹងរួមផ្សំជាមួយនឹងសកម្មភាពរួមគ្នា ។ ជាថ្មីម្តងទៀតសារៈសំខាន់នៃពត៌មាន និងការចូលរួមពាក់ពន្ធ័របស់សង្គមស៊ីវិលរួមទាំងប្រពន្ធ័ផ្សព្វផ្សាយគឺជាចំណុចកណ្តាលមួយ ។

កំណែទំរង់មិនត្រឹមតែផ្តួចផ្តើមឡើង និងគាំទ្រដោយអ្នកនយោបាយ និងអ្នកធ្វើគោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការចូលរួមពីសមាជិកសង្គមស៊ីវិល និងប្រពន្ធ័ផ្សព្វផ្សាយផងដែរ ។ សង្គមស៊ីវិល និងប្រពន្ធ័ផ្សព្វផ្សាយមានសារៈសំខាន់ណាស់ក្នុងការបង្កើត និងថែរក្សាបរិយាកាសនៅក្នុងជីវិតសាធារណៈដែលមិនជំរុញអោយមានការកេងបន្លំ និងពុករលួយ ។

ជាងនេះទៅទៀត នៅពេលដែលតួនាទីសេរីរបស់សារព័ត៌មានដើតួនាទីក្នុងការស៊ើបអង្កេត ធ្វើសេចក្តីរាយការណ៍ហើយនោះ ការជួយប្រយុទ្ធប្រឆាំងអំពើពុករលួយត្រូវបានគេទទួលស្គាល់ ។ ការវាយតំលៃ និងការអត្ថាធិប្បាយនានា អត្ថន័យជាក់លាក់ដែលតាមរយៈនោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអាចអនុវត្តន៍តួនាទីនេះហាក់ដូចជាកម្រណាស់ ទោះបីថាវាមានទំនាក់ទំនងគ្នាយ៉ាងរឹងមាំ រវាងករណីនៃអំពើពុករលួយ និងវិសាលភាពដែលជាប្រពន្ធ័ផ្សព្វផ្សាយមានលក្ខណៈសេរី ។

នៅក្នុងប្រទេសមួយដែលមានប្រព័ន្ធសារព័ត៌មានខ្លាំង និងឯករាជ្យ ជនពុករលួយ និងមន្ត្រីដែលមានពុតត្បុតហាក់ដូចជាមានភាពខ្លាចរអែងក្នុងការប្រព្រឹត្តអំពើពុករលួយ ស៊ីសំណូកសូកប៉ាន់ ។ ខាងក្រោមនេះជាឧទាហរណ៍ខ្លះៗក្នុងការបកអាក្រាត និងទប់ស្កាត់ការរីករាលដាលនៃអំពើពុករលួយស៊ីសំណូកសូកប៉ាន់ ។

ការសែតប្រចាំថ្ងៃឈ្មោះ Hoy បានបង្ហាញថាប្រធានាធិបតី Bucaram បានបង្វែរលុយដែលរៃអង្គាសបានក្នុងយុទ្ធនាការតាមទូរទស្សន៍ក្នុងពេលបុណ្យគ្រិស្តម៉ាស់សំរាប់ជួយអ្នកក្រទៅប្រើប្រាស់ផ្ទាល់ខ្លួន ហើយក៏មានហ្វូងមនុស្សក្រោកឈរឡើងប្រឆាំងយ៉ាងខ្លាំងក្លា ទីបំផុតគាត់ត្រូវបានសមាជបណ្តេញចេញពីអំណាចក្នុងបទអសមត្ថភាពផ្នែកខួរក្បាលនេះដោយសារការស៊ើបអង្កេតរបស់សារពត៌មានខាងលើ ។

នៅប្រទេសវេណេហ្ស៊ូអេឡា រឿងក្តីស៊ើបអង្កេតពីរបានបោះពុម្ពផ្សាយនៅក្នុងសារពត៌មាន Caracas Daily El Universal ត្រូវបានគេទទួលស្គាល់ថាបានធ្វើអោយប្រធានាធិបតី Perez ប្រើប្រាស់ថវិកាចំនួន ១៧ លានដុល្លារដោយមិនស្របច្បាប់ ។ ជាមួយគ្នានេះដែរឯកសារមួយចំនួនបានធ្លាយចេញពីធនាគារកណ្តាល និងក្រសួងការបរទេសបានបង្ហាញថា លោក Perez និងមនុស្សជំនិតពីរនាក់របស់គាត់បានគិបកេងលុយរាប់លានដុល្លារតាម

រយៈការប្តូរប្រាក់ពីរូបិយវត្ថុវេណេហ្ស៊ូអេឡាទៅជាប្រាក់ដុល្លារ ដោយគ្រាន់តែបញ្ចុះតម្លៃប្រាក់ដុល្លារ ។ បន្ទាប់ពីអ្នកធ្វើច្បាប់បញ្ជូនការចោទប្រកាន់ទៅអោយលោក Perez គាត់ត្រូវបានបង្ខំអោយចុះចេញពីតំណែង ។

នៅប្រទេសកូឡុំប៊ី សមាជិកគណរដ្ឋមន្ត្រីពីររូប បានលាចេញពីតំណែងនៅពាក់កណ្តាលឆ្នាំ១៩៧៧ បន្ទាប់ពីទស្សនាវដ្តីប្រចាំសប្តាហ៍សេម៉ាណា (Semana) បានបោះពុម្ពផ្សាយពីការសន្ទនាដែលបានថតចម្លងតាមប្រពន្ធ័ទូរសព្ទ័ដែលក្នុងនោះបានពិភាក្សាគ្នាអំពីផែនការរបស់លោកប្រធានាធិបតី Ernesto Samper ក្នុងការធ្វើសម្បទានប្រហែលពាក់កណ្តាលនៃវិទ្យុរបស់រដ្ឋាភិបាលទៅអោយមិត្តភក្តិរបស់គាត់នេះបើតាមរបាយការណ៍ដែលបានលើកឡើងក្នុង "ការពិនិត្យឡើងវិញសារពត៌មានកូឡុំប៊ី" ។ ផ្នែករួមនៃព័ត៌មានដែលបានបោះពុម្ពផ្សាយពីការទាក់ទងខ្លួនលោក Samper ផ្ទាល់ទៅនឹងការចូលរួមគ្នាជាមួយក្រុមហ៊ុនថ្នាំពេទ្យ Cali ហើយព័ត៌មាននេះបានទទួលនូវការចាប់អារម្មណ៍យ៉ាងខ្លាំងពីអន្តរជាតិ ។ ខណៈពេលដែលលោក Samper បានរួចខ្លួនពីការប៉ុនប៉ងចោទប្រកាន់ និងបានបំរើការងាររហូតដល់ចប់អាណត្តិ រឿងរ៉ាវទាំងអស់នេះបានឈានទៅដល់ការលាឈប់ពីតំណែង និងការចាប់ខ្លួនរដ្ឋមន្ត្រីការពារប្រទេសរបស់គាត់ ។ គេជឿជាក់ថា បញ្ហាទាំងអស់នេះបានធ្វើអោយប៉ះពាល់ដល់ជីវិតនយោបាយរបស់គាត់ និងបាត់បង់ការគាំទ្រទាំងក្នុងប្រទេស និងអន្តរជាតិ ។

នៅសហរដ្ឋអាមេរិក លោក Dan Rostenkowski អតីតសមាជិកសភាជាន់ទាបបានបាត់បង់កៅអីរបស់គាត់បន្ទាប់ពីកាសែត Chicago Sun Times បោះពុម្ពផ្សាយរបាយការណ៍ស៊ើបអង្កេតមួយចំនួនអំពីអ្វីដែលបានកើតឡើងក្នុងរយៈពេលពីរឆ្នាំកន្លះ ។ របាយការណ៍នោះបានបង្ហាញពីរបៀបដែលប្រធានគណៈកម្មការមធ្យោបាយ និងថាមពលរបស់សភា គឺលោក Dan Rostenkowski បានប្រព្រឹត្តកំហុសដោយបានដកលុយរាប់លានដុល្លារពីយុទ្ធនាការរកប្រាក់ និងថវិការវិភាជន៏របស់សភា ។ ការរាយការណ៍បាននាំទៅដល់ការចោទប្រកាន់គាត់នៅ ខែឧសភា ឆ្នាំ១៩៩៤ ហើយបន្ទាប់មកបានរងនូវការបរាជ័យនៅខែវិច្ឆិកា ឆ្នាំ១៩៩៤ នេះ បើតាមរបាយការណ៍ស៊ើបអង្កេតអ្នកយកពតិមាន និងអ្នកបោះពុម្ពផ្សាយដែលជាក្រុមសារព័តិមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ។ លោក Dan Rostenkowski ត្រូវមានទោសពីបទពុករលួយនៅថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៩៦ ។

ក្រៅពីករណីខាងលើនេះនៅមានករណីផ្សេងៗទៀតជាច្រើនដែលប្រមុខរដ្ឋ និងអ្នកនយោបាយត្រូវមានទោស និងបាត់បង់អាជីពជាអ្នកនយោបាយ ដោយសារការប្រព្រឹត្តិអំពើពុករលួយ ។ ហើយជោគជ័យទាំងនោះគឺដោយសារការស៊ើបអង្កេត និងចុះផ្សាយរបស់បណ្តាញសារពតិមាន ។

ជារួមបណ្តាញសារព័តិមានមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់អំពើពុករលួយ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏សារព័តិមានត្រូវតែឈរលើមូលដ្ឋានវិជ្ជាជីវៈ សុចរិត ស្មោះត្រង់ និងមិនលំអៀង ។

សូមអានបន្ថែមឯកសារស្តីពីតួនាទីរបស់ប្រពន្ធ័ផ្សព្វផ្សាយក្នុងការទប់ស្កាត់អំពើពុករលួយដោយលោក Rick Stapenhurst ដែលបានបោះពុម្ពក្នុងឆ្នាំ២០០០ ដោយវិទ្យាស្ថានធនាគារពិភពលោក ។

*អត្ថបទដោយលោក* ***ឯក ស៊ីមែន*** *អ្នកសំរបសំរួលកម្មវិធីបញ្ហាអភិវឌ្ឍន៍ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ។*






វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

ការិយាល័យ ផ្ទះលេខ ៩-១១ ទួលទំពូង ១ ភ្នំពេញ

ទូរស័ព្ទលេខ: ០២៣ ២១៤ ៤២៩

ទូរសារលេខ: ០២៣ ៩៩៤ ០៦៣

E-mail: ngoforum@ngoforum.org.kh

Website: www.ngoforum.org.kh